# សូមចុះឈ្មោះបោះឆ្នោតនៅក្នុងរដ្ឋរបស់អ្នក ដោយទម្រង់បណ្ណ និងការណែនាំនេះ



## សម្រាប់ ពលរដ្ឋសហរដ្ឋអាមេរិក

# ការណែនាំទូទៅ

## អ្នកដែលអាចប្រើពាក្យស្នើសុំនេះ
ប្រសិនបើអ្នកជាពលរដ្ឋសហរដ្ឋអាមេរិកដែលរស់នៅ ឬមានអាស័យដ្ឋាននៅក្នុងសហរដ្ឋអាមេរិក អ្នកអាចប្រើប្រាស់ពាក្យស្នើសុំនៅក្នុងកូនសៀវភៅនេះដើម្បី៖

- សូមចុះឈ្មោះបោះឆ្នោតនៅក្នុងរដ្ឋរបស់អ្នក
- សូមរាយការអំពីការប្តូរឈ្មោះទៅកាន់ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក
- សូមរាយការអំពីការប្តូរអាសយដ្ឋានមោះទៅកាន់ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក
- សូមចុះឈ្មោះជាមួយគណបក្សនយោបាយ។

## ករណីលើកលែង
សូមកុំប្រើពាក្យស្នើសុំនេះ ប្រសិនបើ
អ្នករស់នៅក្រៅសហរដ្ឋអាមេរិក
និងដែនដីរបស់សហរដ្ឋអាមេរិក
និងមិនមានលំនៅស្ថាន(ស្របច្បាប) នៅក្នុងប្រទេសនេះ ឬប្រសិនបើអ្នកនៅក្នុងបន្ទាយយោធាក្រៅប្រទេស។ សូមប្រើពាក្យស្នើសុំបណ្ណប្រៃសណីយ៍សហព័ន្ធដែលមានសម្រាប់អ្នកពីបន្ទាយយោធា ស្ថានទូតសហរដ្ឋអាមេរិក ឬការិយាល័យកុងសុល។

**New Hampshire** ស្នានៃទីក្រុងនិងទីប្រជុំជននឹងទទួលយកទម្រង់បែបបទនេះតែក្នុងករណីមានសំណើចំពោះអវត្តមានអ្នកបោះឆ្នោតដោយផ្ញើចូលនូវទម្រង់ចុះឈ្មោះ។
**នៅ Dakotaខាងជើង** មិន
មានការចុះឈ្មោះអ្នកបោះឆ្នោតទេ។
**នៅរដ្ឋWyoming** ច្បាប់មិនអនុញ្ញាតឲ្យផ្ញើការចុះឈ្មោះឡើយ។

## របៀបពិនិត្យមើលថាតើអ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោតនៅក្នុងរដ្ឋរបស់អ្នកឬទេ
រដ្ឋនីមួយៗមានច្បាប់ផ្ទាល់ខ្លួនអំពីថាតើនរណាអាចចុះឈ្មោះនិងបោះឆ្នោតបាន។ ពិនិត្យមើលព័ត៍មានក្នុងរដ្ឋរបស់អ្នកនៅក្នុងការណែនាំរដ្ឋ។ រដ្ឋទាំងអស់តម្រូវថា អ្នកត្រូវតែជាពលរដ្ឋសហរដ្ឋអាមេរិកពីកំណើត ឬដោយតូបនីយកម្មដើម្បីចុះឈ្មោះបោះឆ្នោតក្នុងការបោះឆ្នោតសហព័ន្ធនិងបោះឆ្នោតរដ្ឋ។ ច្បាប់សហព័ន្ធកំណត់ថាជាអំពើខុសច្បាប់ក្នុងការទាមទារជាពលរដ្ឋសហរដ្ឋអាមេរិកដោយមិនពិតដើម្បីចុះឈ្មោះបោះឆ្នោតនៅក្នុងការបោះឆ្នោតមូលដ្ឋាន រដ្ឋ ឬសហព័ន្ធណាមួយ។ អ្នកមិនអាច ចុះឈ្មោះបោះឆ្នោតលើសពីមួយកន្លែងបានឡើង។

## របៀបនៃការបំពេញពាក្យស្នើសុំនេះ
សូមប្រើការណែនាំសម្រាប់ពាក្យស្នើសុំនិងការណែនាំរដ្ឋដើម្បីប្រាប់អ្នកអំពីការបំពេញពាក្យស្នើសុំនេះ។

- ជាដំបូង ត្រូវអានការណែនាំសម្រាប់ពាក្យស្នើសុំ។ ការណែនាំទាំងនេះនឹងផ្តល់ឲ្យអ្នកនូវព័ត៍មានចាំបាច់ដែលអនុវត្តចំពោះមនុស្សគ្រប់គ្នាដែលប្រើប្រាស់ពាក្យស្នើសុំនេះ។
- បន្ទាប់មក ស្វែងរករដ្ឋរបស់អ្នកនៅក្រោមការណែនាំរដ្ឋ។ ចូរប្រើការណែនាំទាំងនេះដើម្បីបំពេញប្រអប់លេខ 6 7 និង ដោយយោងទៅការណែនាំទាំងនេះសម្រាប់ព័ត៍មានអំពីសិទ្ធិរបស់អ្នកបោះឆ្នោតនិងតម្រូវការស្បថណាមួយសម្រាប់ប្រអប់លេខ 9។

## នៅពេលដែលត្រូវចុះឈ្មោះបោះឆ្នោត
រដ្ឋនីមួយៗមានកាលកំណត់សម្រាប់ចុះឈ្មោះអ្នកបោះឆ្នោតផ្ទាល់ខ្លួន។ សូមពិនិត្យមើលកាលកំណត់សម្រាប់រដ្ឋរបស់អ្នកនៅទំព័រចុងក្រោយនៃកូនសៀវភៅនេះ។

## របៀបដាក់បញ្ជូនពាក្យស្នើសុំរបស់អ្នក
សូមផ្ញើពាក្យស្នើសុំរបស់អ្នកទៅកាន់អាសយដ្ឋានដែលបានរាយនៅក្នុងរដ្ឋរបស់អ្នកនៅក្នុងការណែនាំរដ្ឋ។ ឬក៏ បញ្ជូនពាក្យស្នើសុំដោយផ្ទាល់ទៅកាន់ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក។ រដ្ឋដែលតម្រូវឲ្យទទួលទម្រង់បែបបទជាតិនឹងទទួលយកពាក្យស្នើសុំថតចម្លងដែលបោះពុម្ពចេញពីរូបភាពកុំព្យូទ័រតាមទំហំទៀងទាត់ និងមានចុះហត្ថលេខាដោយអ្នកដាក់ពាក្យស្នើសុំ និងផ្ញើដោយស្រោមសំបុត្រជាមួយអាសយដ្ឋានត្រឹមត្រូវ។

## អ្នកបោះឆ្នោតលើកដំបូងដែលចុះឈ្មោះដោយផ្ញើតាមប្រៃសណីយ៍
ប្រសិនបើអ្នកចុះឈ្មោះបោះឆ្នោតសម្រាប់លើកដំបូងក្នុងយុត្តាធិការរបស់អ្នក និងផ្ញើពាក្យស្នើសុំចុះឈ្មោះតាមប្រៃសណីយ៍ ច្បាប់សហព័ន្ធតម្រូវឲ្យអ្នកបង្ហាញភស្តុតាងបញ្ជាក់អត្តសញ្ញាណនូវការបោះឆ្នោតលើកដំបូងរបស់អ្នក។
ភស្តុតាងបញ្ជាក់អត្តសញ្ញាណរួមមាន៖

- រូបថតអត្តសញ្ញាណមានសុពលភាពនិងបច្ចុប្បន្ន ឬ
- វិក្កយបត្រប្រើប្រាស់ភ្លើងទឹក របាយការណ៍ធនាគារ សែករដ្ឋាភិបាល សែកទូទាត់ឬឯកសាររដ្ឋាភិបាលបច្ចុប្បន្នដែលមានឈ្មោះ និងអាសយដ្ឋានរបស់អ្នក។

អ្នកបោះឆ្នោតអាចលើកលែងលក្ខខណ្ឌនេះ
ប្រសិនបើគេដាក់ជូន ឯកសារថតចម្លង អត្តសញ្ញាណនេះជាមួយទម្រង់ចុះឈ្មោះអ្នកបោះឆ្នោត។ ប្រសិនបើអ្នកចង់ដាក់ឯកសារថតចម្លង សូមចាំនូវចំណុចខាងក្រោម៖

- រដ្ឋរបស់អ្នកអាចមានតម្រូវអត្តសញ្ញាណបន្ថែមទៀត ដែលអាចតំណាងឲ្យអ្នកបង្ហាញអត្តសញ្ញាណនៅកន្លែងបោះឆ្នោត ទោះបីអ្នកបំពេញតាមភស្តុតាងបញ្ជាក់អត្តសញ្ញាណសហព័ន្ធក្តី។
- សូមកុំដាក់បញ្ជូនឯកសារដើមជាមួយនឹងពាក្យស្នើសុំនេះ គឺដាក់តែឯកសារថតចម្លងប៉ុណ្ណោះ។

**ប្រសិនបើអ្នកផ្តល់ពាក្យស្នើសុំនេះនៅភ្នាក់ងាររដ្ឋឬការិយាល័សាធារណៈ**

ប្រសិនបើអ្នកបានផ្តល់ពាក្យស្នើសុំនេះនៅភ្នាក់ងាររដ្ឋ ឬការិយាល័យសាធារណៈ នោះវាគឺជាជម្រើសរបស់អ្នកក្នុងការប្រើពាក្យស្នើសុំនេះ។ ប្រសិនបើអ្នកសម្រេចប្រើពាក្យស្នើសុំនេះក្នុងការចុះឈ្មោះបោះឆ្នោត អ្នកអាចបំពេញវា និងបញ្ជូនវាទៅឲ្យភ្នាក់ងាររដ្ឋ ឬការិយាល័យសាធារណៈ។ ពាក្យស្នើសុំនឹងត្រូវដាក់សម្រាប់អ្នក។ ឬ អ្នកអាចយកវាជាមួយអ្នកហើយផ្ញើពាក្យស្នើសុំរបស់អ្នកទៅកាន់អាសយដ្ឋានដែលបានរាយនៅក្នុងរដ្ឋរបស់អ្នកនៅក្នុងការណែនាំរដ្ឋ។ អ្នកក៏អាចយកវាមកជាមួយដើម្បីបញ្ជូនដោយផ្ទាល់ទៅការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតមូលដ្ឋាន។
សម្គាល់៖ ឈ្មោះ និងទីតាំងនៃភ្នាក់ងាររដ្ឋ ឬការិយាល័យសាធារណៈដែលអ្នកបានទទួលពាក្យស្នើសុំនឹងនៅជាការសម្ងាត់។ វានឹងមិនបង្ហាញនៅលើពាក្យស្នើសុំរបស់អ្នកឡើយ។ ប្រសិនបើអ្នកសម្រេចមិនប្រើពាក្យស្នើសុំនេះដើម្បីចុះឈ្មោះបោះឆ្នោតទេ ការសម្រេចចិត្តនៅក៏នៅជាការសម្ងាត់ផងដែរ។ វានឹងមិនប៉ះពាល់ដល់សេវាដែលអ្នកទទួលពីភ្នាក់ងារឬការិយាល័យទេ។

# ការណែនាំសម្រាប់ពាក្យស្នើសុំ។

មុនពេលបំពេញទម្រង់ពាក្យស្នើសុំនេះ ចូរឆ្លើយសំណួរនៅផ្នែកខាងលើទម្រង់ថាតើអ្នកជាពលរដ្ឋសហរដ្ឋអាមេរិក ឬថាតើអ្នកមានអាយុ18 ឆ្នាំនៅថ្ងៃ ឬមុនថ្ងៃបោះឆ្នោតឬទេ។ ប្រសិនបើអ្នកឆ្លើយថាទេចំពោះសំណួរទាំងនេះ អាចមិនអាចប្រើទម្រង់នេះដើម្បីចុះឈ្មោះបោះឆ្នោតទេ។ ទោះជាយ៉ាងនេះក្ដី ការណែនាំជាក់លាក់របស់រដ្ឋអាចផ្ដល់ឲ្យព័ត៍មានបន្ថែមអំពីសិទ្ធិចុះឈ្មោះបោះឆ្នោតនៅមុនអាយុ 18 ឆ្នាំ។

**ប្រអប់ទី 1 — ឈ្មោះ**
សូមសរសេរឈ្មោះពេញរបស់អ្នកនៅក្នុងប្រអប់នេះតាមលំដាប់ នាមខ្លួននាមត្រកូលនាមកណ្តាល។មិនត្រូវប្រើឈ្មោះហៅក្រៅឬឈ្មោះដើមឡើយ។
*សម្គាល់៖* ប្រសិនបើពាក្យស្នើសុំនេះមិនមែនសម្រាប់ការប្តូរឈ្មោះទេ សូមប្រាប់យើងក្នុង ប្រអប់ A*(នៅកន្លះទំព័រក្រោមនៃទម្រង់)* ឈ្មោះពេញរបស់អ្នកមុនពេលប្តូរវា។

**ប្រអប់ទី 2 អាសយដ្ឋានលំនៅស្ថាន**
សូមសរសេរអាស័យដ្ឋានលំនៅស្ថានរបស់អ្នកនៅក្នុងប្រអប់នេះ (អាស័យដ្ឋានស្របច្បាប់)។ ចូរកុំ ដាក់ អាស័យដ្ឋានប្រៃសណីយ៍របស់អ្នកនៅទីនេះ ប្រសិនបើវាខុសពីអាស័យដ្ឋានលំនៅស្ថាន។ ចូរកុំ ប្រើ ប្រអប់ការិយាល័យប្រៃសណីយ៍ ឬផ្លូវជនបទដោយគ្មានលេខប្រអប់ឡើយ។ យោងទៅការណែនាំជាក់លាក់របស់រដ្ឋសម្រាប់វិធានទាក់ទងនឹងការប្រើប្រាស់លេខផ្លូវ។

*សម្គាល់៖* ប្រសិនបើអ្នកត្រូវបានចុះឈ្មោះពីមុនមក ប៉ុន្តែនេះគឺជាលើកទីមួយដែលអ្នកចុះឈ្មោះពីក្នុងអាសយដ្ឋានក្នុងប្រអប់ទី 2 សូមប្រាប់យើងនៅក្នុង ប្រអប់ B *(នៅពាក់កណ្តាលខាងក្រោមទម្រង់)* អាសយដ្ឋានដែលអ្នកត្រូវបានចុះឈ្មោះពីមុនមក។ សូមប្រាប់យើងអាស័យដ្ឋានឲ្យបានច្រើនតាមដែលអ្នកចាំ។

*សម្គាល់ផងដែរ៖* ប្រសិនបើអ្នករស់នៅទីជនបទ ប៉ុន្តែមិនមានអាសយដ្ឋានផ្លូវ ឬប្រសិនបើគ្មានអាស័យដ្ឋាន សូមបង្ហាញទីកន្លែងដែលអ្នករស់នៅដោយប្រើផែនទីក្នុងប្រអប់ C *(នៅខាងក្រោមទម្រង់នេះ)*។

**ប្រអប់ទី 3 អាស័យដ្ឋានប្រៃសណីយ៍**
ប្រសិនបើអ្នកទទួលសំបុត្រនៅអាស័យដ្ឋានដែលផ្សេងពីអាស័យដ្ឋានក្នុងប្រអប់ទី 2 ចូរដាក់អាស័យដ្ឋានប្រៃសណីយ៍របស់អ្នកនៅក្នុងប្រអប់នេះ។ ប្រសិនបើអ្នកមិនមានអាស័យដ្ឋានក្នុងប្រអប់ 2 អ្នក ត្រូវ សរសេរក្នុងប្រអប់ទី 3 នូវអាសយដ្ឋានដែលអ្នកអាចទទួលដោយការផ្ញើនេះ។

**ប្រអប់ទី 4 ថ្ងៃខែឆ្នាំកំណើត**
សូមសរសេរថ្ងៃខែឆ្នាំកំណើតរបស់អ្នកតាមលំដាប់នៅក្នុងប្រអប់នេះ ខែ ថ្ងៃ ឆ្នាំ។ *ប្រយ័ត្នមិនត្រូវប្រើកាលបរិច្ឆេទថ្ងៃនេះទេ!*

**ប្រអប់ទី 5 លេខទូរស័ព្ទ**
រដ្ឋជាច្រើនស្នើសុំលេខទូរស័ព្ទរបស់អ្នក ក្នុងករណីដែលមានសំណួរអំពីពាក្យស្នើសុំរបស់អ្នក។ ទោះជាយ៉ាងនេះក្តី អ្នកមិនត្រូវបំពេញនៅក្នុងប្រអប់នេះទេ។

**ប្រអប់ទី 6 លេខអត្តសញ្ញាណបណ្ណ**
ច្បាប់សហព័ន្ធតម្រូវថា រដ្ឋត្រូវប្រមូលលេខអត្តសញ្ញាណនៃអ្នកចុះឈ្មោះម្នាក់ៗ។ អ្នកត្រូវយោងទៅការណែនាំជាក់លាក់របស់រដ្ឋសម្រាប់ចំណុច 6 ទាក់ទងនឹងព័ត៍មានអំពីលេខណាដែលបានទទួលសម្រាប់រដ្ឋរបស់អ្នក។ ប្រសិនបើអ្នកគ្មានលេខបណ្ណបើកបរ ឬលេខសន្តិសុខសង្គម ចូរបង្ហាញនៅលើទម្រង់នេះ និងលេខត្រូវបញ្ជូនទៅឲ្យអ្នកដោយរដ្ឋ។

**ប្រអប់ទី 7 ជម្រើសបក្ស**
នៅក្នុងរដ្ឋខ្លះ អ្នកត្រូវចុះឈ្មោះជាមួយបក្សប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬអនុសញ្ញា។ ដើម្បីដឹងថារដ្ឋរបស់អ្នកតម្រូវលក្ខខណ្ឌនេះ សូមមើលចំណុច 7 នៅក្នុងការណែនាំនៅក្នុងរដ្ឋរបស់អ្នក។

ប្រសិនបើអ្នកចង់ចុះឈ្មោះជាមួយគណៈបក្ស ចូរសរសេរនៅក្នុងប្រអប់នូវឈ្មោះពេញនៃគណៈបក្សដែលជាជម្រើសរបស់អ្នក។

ប្រសិនបើអ្នកមិនចង់ចុះឈ្មោះជាមួយគណៈបក្សណាមួយទេ ចូរសរសេរ “គ្មានបក្ស” ឬទុកប្រអប់នៅទំនេរ។ សូមកុំសរសេរពាក្យ “ឯករាជ្យ” ប្រសិនបើអ្នកចង់មានន័យថា “គ្មានបក្ស” ពីព្រោះវាអាចច្រឡំជាមួយឈ្មោះគណៈបក្សនៅក្នុងរដ្ឋរបស់អ្នក។
*សម្គាល់៖* ប្រសិនបើអ្នកមិនចុះឈ្មោះជាមួយគណៈបក្សទេ អ្នកនៅតែអាចបោះឆ្នោតទូទៅនិងដោយគ្មានបក្សពួក (គ្មានបក)នូវការប៉ោឆ្នោតបឋម។

**ប្រអប់ទី 8 សាសន៍ ឬក្រុមជនជាតិ**
រដ្ឋមួយចំនួនតូចស្នើសុំបញ្ជាក់អំពីសាសន៍ឬក្រុមជនជាតិដើម្បីគ្រប់គ្រងទៅតាមច្បាប់ស្តីពីសិទ្ធិបោះឆ្នោតសហព័ន្ធ។ ដើម្បីដឹងថារដ្ឋរបស់អ្នកស្នើសុំរកព័ត៍មាននេះឬអត់ សូមមើលចំណុច 8 នៅក្នុងការណែនាំនៅក្នុងរដ្ឋរបស់អ្នក។ ប្រសិនបើរដ្ឋរបស់អ្នកតម្រូវដូច្នេះ ចូរសរសេរនៅក្នុងប្រអប់ទី 8 នូវជម្រើសដែលពិពណ៌នាល្អបំផុតពីអ្នកនូវតារាងខាងក្រោម៖

- ពលរដ្ឋឥណ្ឌាអាមេរិក *ឬ* ជនជាតិដើមអាឡាស្កា
- ពលរដ្ឋអាស៊ី ឬកោះប៉ាស៊ីហ្វិក
- ជនជាតិស្បែកខ្មៅ *មិនមែន* អំបូរដើមអេស្ប៉ាញ
- អេស្ប៉ាញ
- ជាតិសាសន៍ចម្រុះ
- ជនជាតិស្បែកស *មិនមែន* អំបូរដើមអេស្ប៉ាញ
- ផ្សេងៗ

**ប្រអប់ទី 9 ហត្ថលេខា**
សូមពិនិត្យមើលព័ត៍មានក្នុងចំណុចទី 9 ក្នុងការណែនាំរបស់រដ្ឋរបស់អ្នកឡើងវិញ។ មុនពេលអ្នកចុះហត្ថលេខា ឬធ្វើសញ្ញាសម្គាល់ អ្នកត្រូវប្រាកដថា៖

(1) អ្នកបំពេញតាមលក្ខខណ្ឌតម្រូវរបស់រដ្ឋរបស់អ្នក និង
(2) អ្នកយល់ព័ត៍មាន ក្នុងប្រអប់ ទី 9 ទាំងអស់។

ចុងក្រោយ ហត្ថលេខាឈ្មោះ ពេញ របស់អ្នក ឬធ្វើសញ្ញាសម្គាល់ និងចុះកាលបរិច្ឆេទ តាមលំដាប់ ខែ ថ្ងៃ ឆ្នាំ។ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំមិនអាចចុះហត្ថលេខា ចូរសរសេរក្នុង ប្រអប់ D ឈ្មោះ អាស័យដ្ឋាន និងលេខទូរស័ព្ទ (ជម្រើស)របស់បុគ្គលដែលបានជួយអ្នកដាក់ពាក្យស្នើសុំ។

# ពាក្យស្នើសុំចុះឈ្មោះអ្នកបោះឆ្នោត

**Before completing this form, review the General, Application, and State specific instructions.**
មុនបំពេញទម្រង់ស្នើសុំនេះ ចូរពិនិត្យមើលសេចក្តីណែនាំជាក់លាក់រដ្ឋ សេចក្តីណែនាំពាក្យស្នើសុំ និងសេចក្តីណែនាំទូទៅ។
**PLEASE PROVIDE YOUR RESPONSES IN ENGLISH. / សូមផ្តល់ចម្លើយជាភាសាអង់គ្លេស។**

Are you a citizen of the United States of America? ☐
តើអ្នកជាពលរដ្ឋសហរដ្ឋអាមេរិកមែនទេ ?

Will you be 18 years old on or before election day? ☐
តើអ្នកនឹងមានអាយុ 18 ឆ្នាំនៅមុន ឬនៅថ្ងៃបោះឆ្នោតឬទេ ?

**If you checked "No" in response to either of these questions, do not complete form.**
ប្រសិនបើអ្នកគូស "ទេ" ឆ្លើយទៅសំណួរណាមួយ កុំបំពេញទម្រង់នេះ។
(Please see state-specific instructions for rules regarding eligibility a register prior to age 18.)
( សូមមើលសេចក្តីណែនាំជាក់លាក់រដ្ឋសម្រាប់វិធានទាក់ទងសិទ្ធិចុះឈ្មោះមុនមានអាយុ 18 ឆ្នាំ។ )

This space for office use only. / ចន្លោះនេះសម្រាប់មន្ត្រីប្រើប៉ុណ្ណោះ។

| | | | | | | |
|---|---|---|---|---|---|---|
| **1** | ☐ | Last Name / នាមត្រកូល | First Name / នាមខ្លួន | Middle Name(s) / នាមកណ្តាល | | ☐ |
| **2** | Home Address / Dirección donde vive | | Apt. or Lot # / Nº. de depto. o lote | City/Town / ទីក្រុង | State / រដ្ឋ | Zip Code / កូដប្រៃ |
| **3** | Address Where You Get Your Mail If Different From Above / អាសយដ្ឋានដែលអ្នកទទួលម៉ែល បើខុសគ្នាពីអាសយដ្ឋានខាងលើ | | | City/Town / ទីក្រុង | State / រដ្ឋ | Zip Code / កូដប្រៃ |

| | | | | | |
|---|---|---|---|---|---|
| **4** | Date of Birth/ ថ្ងៃខែឆ្នាំកំណើត<br>Month / ខែ Day / ថ្ងៃ Year / ឆ្នាំ | **5** | Telephone Number (optional) / លេខទូរស័ព្ទ ( ជម្រើស ) | **6** | ID Number (See Item 6 in the instructions for your state) / លេខ ID — ( សូមមើលចំណុច 6 នៅក្នុងសេចក្តីណែនាំសម្រាប់រដ្ឋរបស់អ្នក ) |
| **7** | Choice of Party (see item 7 in the instructions for your State) / ជម្រើសបក្ស ( សូមមើលចំណុច 7 នៅក្នុងសេចក្តីណែនាំសម្រាប់រដ្ឋរបស់អ្នក ) | **8** | Race or Ethnic Group (see item 8 in the instructions for your State) / សាសន៍ឬក្រុមជនជាតិ ( សូមមើលចំណុច 8 នៅក្នុងសេចក្តីណែនាំសម្រាប់រដ្ឋរបស់អ្នក ) | | |

**9**

I have reviewed my state's instructions and I swear/affirm that: / ខ្ញុំបានពិនិត្យមើលសេចក្តីណែនាំរបស់រដ្ឋរបស់ខ្ញុំ ហើយខ្ញុំសូមសច្ចាប្រណិធាន/បញ្ជាក់ថា៖

- I am a United States citizen. / ខ្ញុំគឺជាពលរដ្ឋសហរដ្ឋអាមេរិក
- I meet the eligibility requirements of my state and subscribe to any oath required. / ខ្ញុំបានបំពេញតាមលក្ខខណ្ឌទទួលសិទ្ធិនៃរដ្ឋរបស់ខ្ញុំនិងបង្ហាញសម្រាប់ការសម្បថដែលជាការតម្រូវណាមួយ។
- The information I have provided is true to the best of my knowledge under penalty of perjury. If I have provided false information, I may be fined, imprisoned, or (if not a U.S. citizen) deported from or refused entry to the United States. / ព័ត៌មានដែលខ្ញុំបានផ្តល់គឺការពិតតាមការយល់ដឹងរបស់ខ្ញុំស្ថិតក្រោមពិន័យសម្បថ។ ប្រសិនបើខ្ញុំផ្តល់ព័ត៌មានមិនពិត ខ្ញុំអាចត្រូវទទួលទោស ជាប់ពន្ធនាគារ ឬ( ប្រសិនបើខ្ញុំមិនមែនជាពលរដ្ឋសហរដ្ឋអាមេរិក )បានចាកចេញពី ឬបដិសេធចូលក្នុងសហរដ្ឋអាមេរិក។

Please sign full name (or put mark) / សូមចុះហត្ថលេខាឈ្មោះពេញ ( ឬដាក់សញ្ញាសម្គាល់ )

Date / កាលបរិច្ឆេទ៖ Month / ខែ Day / ថ្ងៃ Year / ឆ្នាំ

**If you are registering to vote for the first time:** please refer to the application instructions for information on submitting copies of valid identification documents with this form.
ប្រសិនបើអ្នកចុះឈ្មោះបោះឆ្នោតសម្រាប់លើកដំបូង៖ សូមយោងទៅសេចក្តីណែនាំពាក្យស្នើសុំសម្រាប់ព័ត៌មានលើការដាក់កសារថតចម្លងបញ្ជាក់អត្តសញ្ញាណមានសុពលភាពជាមួយនឹងទម្រង់នេះ។

## *Please fill out the sections below if they apply to you.*
## សូមបំពេញផ្នែកខាងក្រោម ប្រសិនបើពួកគេស្នើមកកាន់អ្នក។

If this application is for a **change of name**, what was your name before you changed it? / ប្រសិនបើពាក្យស្នើសុំនេះគឺសម្រាប់ **ការប្តូរឈ្មោះ** តើអ្នកឈ្មោះអ្វីមុនពេលអ្នកប្តូរវា ?

| | | | | | | |
|---|---|---|---|---|---|---|
| **A** | ☐ | Last Name / នាមត្រកូល | First Name / នាមខ្លួន | Middle Name(s) / នាមកណ្តាល | | ☐ |

If you were **registered before but this is the first time you are registering from the address in Box 2**, what was your address where you were registered before?
ប្រសិនបើអ្នកត្រូវបានចុះឈ្មោះពីមុនមក ប៉ុន្តែនេះគឺជាលើកទីមួយដែលអ្នកចុះឈ្មោះពីក្នុងអាសយដ្ឋានក្នុងប្រអប់ទី 2 តើអាសយដ្ឋានរបស់អ្នកនៅឯណានៅពេលអ្នកចុះឈ្មោះពីមុន ?

| | | | | | |
|---|---|---|---|---|---|
| **B** | Street (or route and box number) / ផ្លូវ ( ផ្លូវលំនិងលេខប្រអប់ ) | Apt. or Lot # / Apt. or Lot # | City/Town/County / ទីក្រុង/ខោនធី | State / រដ្ឋ | Zip Code / កូដប្រៃ |

If you live in a rural area but do not have a street number, or if you have no address, please show on the map where you live.
ប្រសិនបើអ្នករស់នៅទីជនបទ ប៉ុន្តែមិនមានអាសយដ្ឋានផ្លូវ ឬប្រសិនបើគ្មានអាសយដ្ឋាន សូមបង្ហាញផែនទីកន្លែងដែលអ្នក។

**C**

- Write in the names of the crossroads (or streets) nearest to where you live. / សរសេរឈ្មោះផ្លូវខ្វែង ( ឬផ្លូវ )នៅជិតកន្លែងដែលអ្នករស់នៅ។
- Draw an X to show where you live. / គូស X ដើម្បីបង្ហាញកន្លែងដែលអ្នករស់នៅ។
- Use a dot to show any schools, churches, stores, or other landmarks near where you live, and write the name of the landmark. / ប្រើចំណុចដើម្បីបង្ហាញសាលា ព្រះវិហារ ហាង ឬទីសម្គាល់ណាមួយនៅជិតដែលអ្នករស់នៅ និងសរសេរឈ្មោះចំណុចនោះ។

Example / ឧទាហរណ៍




NORTH / ទិសខាងជើង ↑

If the applicant is unable to sign, who helped the applicant fill out this application? Give name, address and phone number (phone number optional).
ប្រសិនបើអ្នកដាក់ពាក្យមិនអាចចុះហត្ថលេខាបាន តើនរណាជាអ្នកជួយអ្នកដាក់ពាក្យស្នើសុំបំពេញពាក្យស្នើសុំនេះ ? ផ្តល់ឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទ ( លេខទូរស័ព្ទជាជម្រើស )។

| | |
|---|---|
| **D** | |

## Mail this application to the address provided for your State.
## ផ្ញើពាក្យស្នើសុំនេះទៅអាសយដ្ឋានដែលបានផ្តល់សម្រាប់រដ្ឋរបស់អ្នក។

# សម្រាប់មន្ត្រីបំពេញប៉ុណ្ណោះ

កម្រិតទីមួយ
ត្រា
ការចាំបាច់
សម្រាប់
ផ្ញើតាមប្រៃសណីយ៍

OFFICIAL
ELECTION MAIL
Authorized by the U.S. Postal Service ®

# ពាក្យស្នើសុំចុះឈ្មោះអ្នកបោះឆ្នោត

**Before completing this form, review the General, Application, and State specific instructions.**

មុនបំពេញទម្រង់ស្នើសុំនេះ ចូរពិនិត្យមើលសេចក្តីណែនាំជាក់លាក់រដ្ឋ សេចក្តីណែនាំពាក្យស្នើសុំ និងសេចក្តីណែនាំទូទៅ។

**PLEASE PROVIDE YOUR RESPONSES IN ENGLISH. / សូមផ្តល់ចម្លើយជាភាសាអង់គ្លេស។**

Are you a citizen of the United States of America? / តើអ្នកជាពលរដ្ឋសហរដ្ឋអាមេរិកមែនទេ? ☐ Yes / បាទ ☐ No / ទេ

Will you be 18 years old on or before election day? / តើអ្នកនឹងមានអាយុ 18 ឆ្នាំនៅមុន ឬនៅថ្ងៃបោះឆ្នោតឬទេ? ☐ Yes / បាទ ☐ No / ទេ

This space for office use only. / ចន្លោះនេះសម្រាប់មន្ត្រីប្រើប៉ុណ្ណោះ។

**If you checked "No" in response to either of these questions, do not complete form.**

ប្រសិនបើអ្នកគូស "ទេ" ឆ្លើយទៅសំណួរណាមួយ កុំបំពេញទម្រង់នេះ។

(Please see state-specific instructions for rules regarding eligibility to register prior to age 18.)

( សូមមើលសេចក្តីណែនាំជាក់លាក់រដ្ឋសម្រាប់វិធានទាក់ទងសិទ្ធិចុះឈ្មោះមុនមានអាយុ 18 ឆ្នាំ។ )

| | | | | | |
|---|---|---|---|---|---|
| **1** | (Circle one) / ( គូសរង្វង់លើចម្លើយមួយ ) Mr. / លោក Mrs. / លោកស្រី Miss / កញ្ញា Ms. / លោក លោកស្រី | Last Name / នាមត្រកូល | First Name / នាមខ្លួន | Middle Name(s) / នាមកណ្តាល | (Circle one) / ( គូសរង្វង់លើចម្លើយមួយ ) Jr. Sr. II III IV |
| **2** | Home Address / អាសយដ្ឋានលំនៅស្ថាន | Apt. or Lot # / Apt. or Lot # | City/Town / ទីក្រុង | State / រដ្ឋ | Zip Code / កូដប្រៃ |
| **3** | Address Where You Get Your Mail If Different From Above / អាសយដ្ឋានដែលអ្នកទទួលម៉ែល បើខុសគ្នាពីអាសយដ្ឋានខាងលើ | | City/Town / ទីក្រុង | State / រដ្ឋ | Zip Code / កូដប្រៃ |

| | | | | | |
|---|---|---|---|---|---|
| **4** | Date of Birth / ថ្ងៃខែឆ្នាំកំណើត<br>Month / ខែ Day / ថ្ងៃ Year / ឆ្នាំ | **5** | Telephone Number (optional) / លេខទូរស័ព្ទ ( ជម្រើស ) | **6** | ID Number (See Item 6 in the instructions for your state) / លេខ ID — ( សូមមើលចំណុច 6 នៅក្នុងសេចក្តីណែនាំសម្រាប់រដ្ឋរបស់អ្នក ) |
| **7** | Choice of Party (see item 7 in the instructions for your State) / ជម្រើសបក្ស ( សូមមើលចំណុច 7 នៅក្នុងសេចក្តីណែនាំសម្រាប់រដ្ឋរបស់អ្នក ) | **8** | Race or Ethnic Group (see item 8 in the instructions for your State) / សាសន៍ឬក្រុមជនជាតិ ( សូមមើលចំណុច 8 នៅក្នុងសេចក្តីណែនាំសម្រាប់រដ្ឋរបស់អ្នក ) | | |

**9**

I have reviewed my state's instructions and I swear/affirm that: / ខ្ញុំបានពិនិត្យមើលសេចក្តីណែនាំរបស់រដ្ឋរបស់ខ្ញុំ ហើយខ្ញុំសូមសច្ចាប្រណិធាន/បញ្ជាក់ថា៖

- I am a United States citizen. / ខ្ញុំគឺជាពលរដ្ឋសហរដ្ឋអាមេរិក
- I meet the eligibility requirements of my state and subscribe to any oath required. / ខ្ញុំបានបំពេញតាមលក្ខខណ្ឌទទួលសិទ្ធិនៃរដ្ឋរបស់ខ្ញុំនិងបង្ហាញសម្របការសម្បថដែលជាការតម្រូវណាមួយ។
- The information I have provided is true to the best of my knowledge under penalty of perjury. If I have provided false information, I may be fined, imprisoned, or (if not a U.S. citizen) deported from or refused entry to the United States. / ព័ត៌មានដែលខ្ញុំបានផ្តល់គឺការពិតតាមការយល់ដឹងរបស់ខ្ញុំស្ថិតក្រោមពិន័យសម្បថ។ ប្រសិនបើខ្ញុំផ្តល់ព័ត៌មានមិនពិត ខ្ញុំអាចត្រូវទទួលទោស ជាប់ពន្ធនាគារ ឬ( ប្រសិនបើខ្ញុំមិនមែនជាពលរដ្ឋសហរដ្ឋអាមេរិក )ហនិរទេសចេញ ឬបដិសេធមិនឲ្យចូលក្នុងសហរដ្ឋអាមេរិក។

Please sign full name (or put mark) / សូមចុះហត្ថលេខាឈ្មោះពេញ ( ឬដាក់សញ្ញាសម្គាល់ )

Date / កាលបរិច្ឆេទ៖ Month / ខែ Day / ថ្ងៃ Year / ឆ្នាំ

**If you are registering to vote for the first time:** please refer to the application instructions for information on submitting copies of valid identification documents with this form.

ប្រសិនបើអ្នកចុះឈ្មោះបោះឆ្នោតសម្រាប់លើកដំបូង៖ សូមយោងទៅសេចក្តីណែនាំពាក្យស្នើសុំសម្រាប់ព័ត៌មានលើការដាក់ឯកសារថតចម្លងបញ្ជាក់អត្តសញ្ញាណមានសុពលភាពជាមួយនឹងទម្រង់នេះ។

## *Please fill out the sections below if they apply to you.*

## សូមបំពេញផ្នែកខាងក្រោម ប្រសិនបើពួកគេស្នើមកកាន់អ្នក។

If this application is for a **change of name**, what was your name before you changed it? / ប្រសិនបើពាក្យស្នើសុំនេះគឺសម្រាប់ **ការប្តូរឈ្មោះ** តើអ្នកឈ្មោះអ្វីមុនពេលអ្នកប្តូរវា?

| | | | | | |
|---|---|---|---|---|---|
| **A** | Mr. / លោក<br>Mrs. / លោកស្រី<br>Miss / កញ្ញា<br>Ms. / លោក លោកស្រី | Last Name / នាមត្រកូល | First Name / នាមខ្លួន | Middle Name(s) / នាមកណ្តាល | (Circle one) / ( គូសរង្វង់លើចម្លើយមួយ ) Jr. Sr. II III IV |

If you were **registered before but this is the first time you are registering from the address in Box 2**, what was your address where you were registered before?

ប្រសិនបើអ្នកត្រូវបានចុះឈ្មោះពីមុនមក ប៉ុន្តែនេះគឺជាលើកទីមួយដែលអ្នកចុះឈ្មោះពីក្នុងអាសយដ្ឋានក្នុងប្រអប់ទី 2 តើអាសយដ្ឋានរបស់អ្នកនៅឯណានៅពេលអ្នកចុះឈ្មោះពីមុន?

| | | | | | |
|---|---|---|---|---|---|
| **B** | Street (or route and box number) / ផ្លូវ ( ផ្លូវលំនិងលេខប្រអប់ ) | Apt. or Lot # / Apt. or Lot # | City/Town/County / ទីក្រុង/ខោនធី | State / រដ្ឋ | Zip Code / កូដប្រៃ |

If you live in a rural area but do not have a street number, or if you have no address, please show on the map where you live.

ប្រសិនបើអ្នករស់នៅទីជនបទ ប៉ុន្តែមិនមានអាសយដ្ឋានផ្លូវ ឬប្រសិនបើគ្មានអាសយដ្ឋាន សូមបង្ហាញផែនទីកន្លែងដែលអ្នក។

**C**

- Write in the names of the crossroads (or streets) nearest to where you live. / សរសេរឈ្មោះផ្លូវខ្វែង ( ឬផ្លូវ )នៅជិតកន្លែងដែលអ្នករស់នៅ។
- Draw an X to show where you live. / គូស X ដើម្បីបង្ហាញកន្លែងដែលអ្នករស់នៅ។
- Use a dot to show any schools, churches, stores, or other landmarks near where you live, and write the name of the landmark. / ប្រើចំណុចដើម្បីបង្ហាញសាលា ព្រះវិហារ ហាង ឬទីសម្គាល់ណាមួយនៅជិតដែលអ្នករស់នៅ និងសរសេរឈ្មោះចំណុចនោះ។




**NORTH / ទិសខាងជើង ↑**

If the applicant is unable to sign, who helped the applicant fill out this application? Give name, address and phone number (phone number optional).

ប្រសិនបើអ្នកដាក់ពាក្យមិនអាចចុះហត្ថលេខាបាន តើនរណាជាអ្នកជួយអ្នកដាក់ពាក្យស្នើសុំបំពេញពាក្យស្នើសុំនេះ? ផ្តល់ឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទ ( លេខទូរស័ព្ទជាជម្រើស )។

**D**

## Mail this application to the address provided for your State.

## ផ្ញើពាក្យស្នើសុំនេះទៅអាសយដ្ឋានដែលបានផ្តល់សម្រាប់រដ្ឋរបស់អ្នក។

# សម្រាប់មន្ត្រីបំពេញប៉ុណ្ណោះ

កម្រិតទីមួយ
ត្រា
ការចាំបាច់
សម្រាប់
ផ្ញើតាមប្រៃសណីយ៍

OFFICIAL
ELECTION MAIL
Authorized by the U.S. Postal Service ®

# ការណែនាំរដ្ឋ

## រដ្ឋ Alabama

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី28 សីហា ឆ្នាំ2017**

**កាលកំណត់ការចុះឈ្មោះ** — ការចុះឈ្មោះអ្នកបោះឆ្នោតត្រូវបិទក្នុងរយៈពេលដប់បួនថ្ងៃមុនការបោះឆ្នោត។ ពាក្យស្នើសុំត្រូវបញ្ជាក់នៅលើបណ្ណប្រៃសណីយ៍ឬបញ្ជូនក្នុងរយៈពេលដប់ប្រាប់ឆ្នាំមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ**
ប្រសិនបើអ្នកមានបណ្ណ អ្នកត្រូវផ្តល់លេខសម្គាល់បណ្ណបើករដ្ឋ Alabama ឬលេខអត្តសញ្ញាណបណ្ណមិនមែនអ្នកបើបករដ្ឋ Alabamaរបស់អ្នក។ ប្រសិនបើអ្នកមិនមានបណ្ណបើកបររដ្ឋ Alabama ឬអត្តសញ្ញាណបណ្ណទេ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ប្រសិនបើអ្នកមិនធ្លាប់ត្រូវចេញបណ្ណណាមួយឲ្យទេ អ្នកត្រូវសរសេរថា "គ្មាន" ហើយការកំណត់តែមួយនឹងត្រូវផ្តល់ឲ្យអ្នក។

**7។ ជម្រើសបក្ស។ ជម្រើស៖**
អ្នកមិនចាំបាច់ត្រូវតែចុះឈ្មោះជាមួយបក្សទេ ប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬសមាជ។

**8។ សាសន៍ ឬក្រុមជនជាតិ អ្នកត្រូវ**តម្រូវឲ្យបំពេញក្នុងប្រអប់នេះ ទោះជាយ៉ាងនេះក្តី ពាក្យស្នើសុំរបស់អ្នកនឹងមិនត្រូវបានបដិសេធឡើយ បើអ្នកមិនបានបំពេញតាមនោះ។ សូមមើលបញ្ជីជម្រើសនៅក្នុងការណែនាំសម្រាប់ពាក្យស្នើសុំនៅប្រអប់ទី 8 (នៅទំព័រ 2)។

**9។ ហត្ថលេខា។ ដើម្បីចុះឈ្មោះ**នៅក្នុងរដ្ឋ Alabama អ្នកត្រូវ៖

- ជាពលរដ្ឋសហរដ្ឋអាមេរិក។
- ស្នាក់នៅក្នុងរដ្ឋ Alabamaនិងជាខោនធីរបស់អ្នកនៅពេលចុះឈ្មោះ
- មានអាយុ 18 ឆ្នាំនៅពេលថ្ងៃបោះឆ្នោត
- មិនត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋពាក់ព័ន្ធសីលធម៌ (មានការស្តារសិទ្ធិពលរដ្ឋនិងនយោបាយ)
- មិនត្រូវបានប្រកាសថាអសមត្ថភាពផ្នែកស្មារតីដោយតុលាការ
- ស្បថ ឬបញ្ជាក់ក្នុងការ "គាំទ្រនិងការពាររដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក និងរដ្ឋ Alabama និងថែមទាំងបដិសេធរាល់ជំនឿឬមានសម្ព័ន្ធភាពជាមួយក្រុមដែលផ្សព្វផ្សាយផ្តួលរំលំរដ្ឋាភិបាលសហរដ្ឋអាមេរិក ឬរដ្ឋ Alabama ដោយវិធីខុសគច្បាប់ ហើយដែលព័ត៌មាននៅក្នុងពាក្យស្នើសុំនេះគឺត្រឹមត្រូវ ដូច្នេះសូមព្រះជាម្ចាស់ជួយខ្ញុំ"

**អាស័យដ្ឋានប្រៃសណីយ៍**

ការិយាល័យលេខាធិការរដ្ឋ
P.O. ប្រអប់ 5616
Montgomery, AL 36103-5616

## រដ្ឋ Alaska

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ — 30** ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** អ្នកត្រូវផ្តល់លេខបញ្ជាក់អត្តសញ្ញាណណាមួយដូចខាងក្រោម លេខបណ្ណបើកបររបសរដ្ឋ Alaska ឬលេខអត្តសញ្ញាណបណ្ណរដ្ឋ Alaska។ ប្រសិនបើអ្នកមិនមានបណ្ណបើកបររបសរដ្ឋ Alaska ឬអត្តសញ្ញាណបណ្ណទេ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ប្រសិនបើអ្នកមិនមានលេខបញ្ជាក់អត្តសញ្ញាណទាំងនេះទេ សូមសរសេរ "គ្មាន" នៅលើទម្រង់នេះ។ លេខបញ្ជាក់អត្តសញ្ញាណតែមួយគត់នឹងត្រូវផ្តល់ឲ្យអ្នកសម្រាប់គោលបំណងការចុះឈ្មោះបោះឆ្នោត។ ព័ត៌មាននេះជាព័ត៌មានសម្ងាត់។ មានព័ត៌មាននេះជួយក្នុងការរក្សាកំណត់ហេតុអ្នកបោះឆ្នោតរបស់អ្នក និងអាចជួយក្នុងការបញ្ជាក់អត្តសញ្ញាណរបស់អ្នក (គន្លឹះទី15នៃធម្មនុញ្ញរដ្ឋ Alaska)។

**7។ ជម្រើសបក្ស។** អ្នកមិនចាំបាច់ប្រកាសអំពីសម្ព័ន្ធភាពជាមួយបក្សនៅពេលចុះឈ្មោះបោះឆ្នោតទេ។ ប្រសិនបើអ្នកមិនជ្រើសបក្សណាមួយ អ្នកនឹងត្រូវចុះឈ្មោះជាអ្នកមិនបានប្រកាស។ រដ្ឋ Alaska មានប្រព័ន្ធបោះឆ្នោតបឋមបិទ។ បក្សនយោបាយដែលបានទទួលស្គាល់នីមួយៗមានបញ្ជីឆ្នោតដាច់ដោយឡែករាយឈ្មោះតែបេក្ខជនមកពីគណៈបក្សនោះប៉ុណ្ណោះ។ ការចុះឈ្មោះអ្នកបោះឆ្នោតជាសមាជិកគណបក្សនយោបាយអាចបោះឆ្នោតតែសន្លឹកឆ្នោតបក្សនោះតែប៉ុណ្ណោះ។ អ្នកបោះឆ្នោតដែលចុះឈ្មោះជាអ្នកមិនបានប្រកាស ឬគ្មានបក្ស អាចជ្រើសសន្លឹកឆ្នោតមួយចេញពីសន្លឹកឆ្នោតដែលមាន។

**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ

**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Alaska អ្នកត្រូវ៖

- ជាពលរដ្ឋសហរដ្ឋអាមេរិក
- មានអាយុយ៉ាងតិច 18 ឆ្នាំក្នុងរយៈពេល 90 ថ្ងៃនៃការបំពេញការចុះឈ្មោះនេះ
- មានលំនៅនៅរដ្ឋ Alaska
- មិនត្រូវបានផ្តន្ទាទោសបទឧក្រិដ្ឋ (លើកលែងតែត្រូវទម្លាក់ចោលដោយគ្មានលក្ខខណ្ឌ)
- មិនត្រូវបានចុះឈ្មោះបោះឆ្នោតនៅរដ្ឋផ្សេង

**អាស័យដ្ឋានប្រៃសណីយ៍**

ផ្នែករៀបចំការបោះឆ្នោត
រដ្ឋ Alaska
PO Box 110017
Juneau, AK 99811-0017

## រដ្ឋ Arizona

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ — 29** ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** ទម្រង់ពាក្យស្នើសុំចុះឈ្មោះបោះឆ្នោតរបស់អ្នកត្រូវមានលេខប័ណ្ណបើកបររដ្ឋ Arizona របស់អ្នក ឬអាជ្ញាបណ្ណអត្តសញ្ញាណមិនប្រតិបត្តិការដែលចេញស្របតាម A.R.S. § 28-3165, ប្រសិនបើអាជ្ញាប័ណ្ណនៅមានសុពលភាពនិងបច្ចុប្បន្ន។ ប្រសិនបើអ្នក *មិនមាន* ប័ណ្ណបើកបរបច្ចុប្បន្ននិងមានសុពលភាព ឬប័ណ្ណអត្តសញ្ញាណមិនប្រតិបត្តិការទេ អ្នកត្រូវបញ្ចូលលេខកូដបួនខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក ប្រសិនបើមាន។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបរមានសុពលភាព ឬបណ្ណបញ្ជាក់មិនប្រតិបត្តិការ ឬលេខសន្តិសុខសង្គមទេ ចូរសរសេរ "គ្មាន" នៅលើទម្រង់នេះ។ លេខសម្គាល់មួយនឹងត្រូវចេញឲ្យអ្នកដោយរដ្ឋមន្ត្រី។

**7។ ជម្រើសបក្ស។** ប្រសិនបើអ្នកចុះឈ្មោះក្នុងបក្សនយោបាយដែលគុណណសម្បត្តិសម្រាប់ទទួលស្គាល់សន្លឹកឆ្នោត អ្នកនឹងត្រូវអនុញ្ញាតឲ្យបោះឆ្នោតសន្លឹកឆ្នោតដំបូងសម្រាប់បក្សនោះប្រសិនបើអ្នកចុះឈ្មោះជាអ្នកឯករាជ្យ មិនមានបក្សណាពេ

ញចិត្តឬជាសមាជិកនៃបក្សណាមួយដែលគ្មានគុណវុឌ្ឍិសម្រាប់សន្លឹកឆ្នោត អ្នកអាចជ្រើសនិងបោះឆ្នោតការបោះឆ្នោតដំបូងមួយនៃបក្សនយោបាយដែលបានទទួលស្គាល់។

**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ

**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Arizona អ្នកត្រូវ៖
• ជាពលរដ្ឋសហរដ្ឋអាមេរិក
• មានលំនៅស្ថាននៅរដ្ឋ Arizona និងជាខោនធីរបស់អ្នកយ៉ាងហោចណាស់ 29 ថ្ងៃមុនថ្ងៃបោះឆ្នោតបន្ទាប់
• មានអាយុ 18 ឆ្នាំនៅថ្ងៃឬមុនការបោះឆ្នោតបន្ទាប់
• មិនត្រូវបានផ្តន្ទាទោសក្បត់ជាតិ ឬឧក្រិដ្ឋ (ឬបានទទួលសិទ្ធិពលរដ្ឋឡើងវិញ)
• មិនត្រូវបានប្រកាសថាជាបុគ្គលអសមត្ថភាពដោយតុលាការនាពេលថ្មីៗ

**អាស័យដ្ឋានប្រៃសណីយ៍**
រដ្ឋមន្ត្រី/ការបោះឆ្នោត
1700 W. Washington, ជាន់ទី 7
Phoenix, AZ 85007-2888

## រដ្ឋ Arkansas

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ** — 30 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** ទម្រង់ចុះឈ្មោះបោះឆ្នោតរបស់អ្នកត្រូវមានលេខប័ណ្ណបើកបរដែលចេញដោយរដ្ឋ ឬលេខអត្តសញ្ញាណមិនប្រតិបត្តិការរបស់អ្នក។ ប្រសិនបើអ្នកមិនមានបណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណទេ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបរ ឬប័ណ្ណបញ្ជាក់មិនប្រតិបត្តិការ ឬលេខសន្តិសុខសង្គមទេ ចូរសរសេរ "គ្មាន" នៅលើទម្រង់នេះ។ លេខសម្គាល់មួយនឹងត្រូវចេញឲ្យអ្នកដោយរដ្ឋ។

**7។ ជម្រើសបក្ស។** ជម្រើស។ អ្នកមិនចាំបាច់ត្រូវតែចុះឈ្មោះជាមួយបក្សទេ ប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬសមាជ។

**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ

**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Arkansasអ្នកត្រូវ៖
• ជាពលរដ្ឋសហរដ្ឋអាមេរិក
• រស់នៅក្នុងរដ្ឋ Arkansasនៅអាសយដ្ឋានសរសេរក្នុងប្រអប់ទី 2 ក្នុងពាក្យស្នើសុំនេះ
• មានអាយុយ៉ាងតិច 18 ឆ្នាំមុនការបោះឆ្នោតបន្ទាប់
• មិនត្រូវបានផ្តន្ទាទោសឧក្រិដ្ឋ(ឬត្រូវបានទម្លាក់ចោលឬលើកលែងទោសពេញលេញ)
• មិនទាមទារសិទ្ធិបោះឆ្នោតនៅក្នុងទីកន្លែងផ្សេងទៀត
• មិនធ្លាប់ត្រូវបានសម្រេចថាជាអសមត្ថជនផ្នែកស្មារតីដោយតុលាការមានសមត្ថកិច្ច

**អាស័យដ្ឋានប្រៃសណីយ៍**
រដ្ឋមន្ត្រី
សេវាអ្នកបោះឆ្នោត
P.O. ប្រអប់ 8111
Little Rock, AR 72203-8111

## រដ្ឋ California

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ** — 15 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ**
នៅពេលអ្នកចុះឈ្មោះបោះឆ្នោត អ្នកត្រូវផ្តល់លេខអត្តសញ្ញាណប័ណ្ណ ឬប័ណ្ណបើកបររដ្ឋ California របស់អ្នកបើអ្នកមាន។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបររបស់រដ្ឋ California ឬអត្តសញ្ញាណប័ណ្ណទេ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ប្រសិនបើអ្នកមិនដាក់ព័ត៍មានទាំងនេះទេ អ្នកនឹងត្រូវតម្រូវឲ្យផ្តល់ការបញ្ជាក់ភស្តុតាងនៅពេលអ្នកបោះឆ្នោត។

**7។ ជម្រើសបក្ស។** សូមបញ្ចូលឈ្មោះគណៈបក្សនយោបាយដែលអ្នកចង់ចុះឈ្មោះ។ ប្រសិនបើអ្នកមិនចង់ចុះឈ្មោះជាមួយគណៈបក្សណាមួយទេ សូមបញ្ចូល "បដិសេធក្នុងការបង្ហាញ" នៅក្នុងចន្លោះដែលផ្តល់ឲ្យ។
ច្បាប់រដ្ឋ California អនុញ្ញាតឲ្យអ្នកបោះឆ្នោត ដែល "បដិសេធក្នុងការបង្ហាញ" សម្ព័ន្ធភាពជាមួយគណៈបក្សនយោបាយមានគុណសម្បត្តិណាមួយ ឬមានសម្ព័ន្ធជាមួយគណៈបក្សដែលគ្មានគុណសម្បត្តិក្នុងការបោះឆ្នោតលើកដំបូងនៃគណៈបក្សនយោបាយដែលមានគុណសម្បត្តិដែលដាក់ការជូនដំណឹងជាមួយរដ្ឋមន្ត្រីដែលអនុញ្ញាតឲ្យធ្វើដូច្នេះ។ អ្នកអាចហៅទូរស័ព្ទមកលេខ 1-800-345-VOTE ឬចូលមើលគេហទំព័រ www.sos.ca.gov ដើម្បីរៀនសូត្រថាតើគណៈបក្សនយោបាយណាដែលអនុញ្ញាតអ្នកបោះឆ្នោតគញមានសម្ព័ន្ធចូលរួមក្នុងការបោះឆ្នោតបឋម។

**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ។

**9។ ហត្ថលេខា។ ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ** California អ្នកត្រូវ៖
• ជាពលរដ្ឋសហរដ្ឋអាមេរិក
• មានលំនៅនៅរដ្ឋ California
• មានអាយុយ៉ាងតិច 18 ឆ្នាំនៅពេលបោះឆ្នោតបន្ទាប់
• មិនត្រូវបានផ្តន្ទាទោសជាប់ពន្ធនាគារ ឬឃុំខ្លួនពីបទឧក្រិដ្ឋ
• មិនត្រូវបានសម្រេចសេចក្តីថាអសមត្ថភាពផ្នែកស្មារតីដោយតុលាការនាពេលថ្មីៗហត្ថលេខាតម្រូវជាចាំបាច់។ ប្រសិនបើអ្នកបំពេញតាមលក្ខខណ្ឌដែលបានរៀបរាប់ខាងលើ សូមចុះហត្ថលេខានិងកាលបរិច្ឆេទលើបណ្ណស្នើសុំក្នុងចន្លោះដែលបានផ្តល់។

អាស័យដ្ឋានប្រៃសណីយ៍
រដ្ឋមន្ត្រី
ផ្នែកការបោះឆ្នោត
1500 11th Street
Sacramento, CA 95814

# ការណែនាំរដ្ឋ

## រដ្ឋ Colorado

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី28 ខែមីនា ឆ្នាំ2008**

**កាលកំណត់ចុះឈ្មោះ** — 29 ថ្ងៃមុនការបោះឆ្នោត។ ប្រសិនបើពាក្យស្នើសុំត្រូវបានទទួលតាមប្រៃសណីយ៍ដោយគ្មានសញ្ញាប្រៃសណីយ៍ វាត្រូវបានទទួលក្នុងរយៈពេល 5 ថ្ងៃនៃថ្ងៃបិទការចុះឈ្មោះ។

**6។ លេខអត្តសញ្ញាណបណ្ណ** ទម្រង់ចុះឈ្មោះបោះឆ្នោតរបស់អ្នកត្រូវមានលេខប័ណ្ណបើកបរដែលចេញដោយរដ្ឋ ឬលេខអត្តសញ្ញាណ។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណទេ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបរ ឬប័ណ្ណចេញដោយរដ្ឋ ឬលេខសន្តិសុខសង្គមទេ ចូរសរសេរ "គ្មាន" នៅលើទម្រង់នេះ។ លេខសម្គាល់មួយនឹងត្រូវចេញឲ្យអ្នកដោយរដ្ឋ។
**7។ ជម្រើសបក្ស។** អ្នកត្រូវចុះឈ្មោះជាមួយបក្សប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬអនុសញ្ញា។
**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ
**9។ ហត្ថលេខា។**
ដើម្បីចុះឈ្មោះបោះឆ្នោតក្នុងរដ្ឋ Colorado អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- ស្នាក់នៅក្នុងរដ្ឋ Colorado 30 ថ្ងៃមុនការបោះឆ្នោត
- មានអាយុ 18 ឆ្នាំនៅមុន ឬនៅថ្ងៃបោះឆ្នោត
- មិនត្រូវផ្តន្ទាទោសជាអ្នកទោស ឬទទួលទោសផ្នែកណាមួយតាមច្បាប់

**អាសយដ្ឋានប្រៃសណីយ៍**
រដ្ឋមន្ត្រីរដ្ឋ Colorado
1700 Broadway, Suite 270
Denver, Colorado 80290

## រដ្ឋ Connecticut

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ** — 14 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ**
លេខប័ណ្ណបើកបរនៃរដ្ឋ Connecticut ឬប្រសិនបើមិនមាន លេខសន្តិសុខសង្គមបួនខ្ទង់ចុងក្រោយ។
**7។ ជម្រើសបក្ស។** នៅតែជាជម្រើប៉ុណ្ណោះ ប៉ុន្តែអ្នកត្រូវចុះឈ្មោះជាមួយបក្សប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬអនុសញ្ញា។
**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Connecticut អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- ស្នាក់នៅរដ្ឋស្នាក់នៅរដ្ឋ Connecticutនិងទីក្រុងដែលអ្នកចង់បោះឆ្នោតនិងទីក្រុងដែលអ្នកចង់បោះឆ្នោត
- មានអាយុ 17 ឆ្នាំ។ អ្នកអាចបោះឆ្នោតបាននៅពេលអ្នកមានអាយុ 18 ឆ្នាំ
- បានបំពេញការអនុវត្តទោសនិងត្រូវលើកលែងទោស ប្រសិនបើពីមុនត្រូវបានផ្តន្ទាទោសបទឧក្រិដ្ឋ និងមានសិទ្ធិបោះឆ្នោតវិញដោយមន្ត្រីសម្រាប់អ្នកបោះឆ្នោត។
- មិនត្រូវបានសម្រេចសេចក្តីថាអសមត្ថភាពផ្នែកស្មារតីក្នុងការបោះឆ្នោតដោយតុលាការនាពេលថ្មីៗ

**អាសយដ្ឋានប្រៃសណីយ៍**
រដ្ឋមន្ត្រី
ផ្នែកការបោះឆ្នោត
ផ្លូវ 30 Trinity
Hartford, CT 06106

## រដ្ឋ Delaware

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី07 ខែកុម្ភៈ ឆ្នាំ2012**

**កាលកំណត់ការចុះឈ្មោះបោះឆ្នោត** — ថ្ងៃសៅរ៍ទី 4 មុនពេលការបោះឆ្នោតបឋមឬសកល និង 10 ថ្ងៃមុនការបោះឆ្នោតពិសេស។

**6។ លេខអត្តសញ្ញាណបណ្ណ** ទម្រង់ចុះឈ្មោះបោះឆ្នោតរបស់អ្នកត្រូវមានលេខប័ណ្ណបើកបរដែលចេញដោយរដ្ឋ ឬលេខអត្តសញ្ញាណមិនប្រតិបត្តិការរបស់អ្នក។ ប្រសិនបើអ្នកមិនមានបណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណមិនបើកបរទេ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបរ ឬប័ណ្ណបញ្ជាក់មិនប្រតិបត្តិការ ឬលេខសន្តិសុខសង្គមទេ ចូរសរសេរ "គ្មាន" នៅលើទម្រង់នេះ។ លេខសម្គាល់មួយនឹងត្រូវចេញឲ្យអ្នកដោយរដ្ឋ។
**7។ ជម្រើសបក្ស។** អ្នកត្រូវចុះឈ្មោះជាមួយបក្សប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬអនុសញ្ញា។
**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Delaware អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- ស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងរដ្ឋ Delaware
- មានអាយុយ៉ាងតិច 18 ឆ្នាំនៅថ្ងៃបោះឆ្នោតបន្ទាប់
- ឧក្រិដ្ឋជនមានសិទ្ធិបោះឆ្នោត ប្រសិនបើលក្ខខ័ណ្ឌមួយចំនួនត្រូវបានបំពេញ៖ ការពិន័យនិងទោសបានអនុវត្តយ៉ាងតិចប្រាំឆ្នាំមុនកាលបរិច្ឆេទពាក្យស្នើសុំ។ ការផ្តន្ទាទោសឧក្រិដ្ឋមិនអាចបោះបង់គុណវុឌ្ឍិជាឧក្រិដ្ឋជន ដូចជាបទមនុស្សឃាត បទល្មើសរំលោភផ្លូវភេទ ឬឧក្រិដ្ឋកម្មប្រឆាំងរដ្ឋបាលសាធារណៈពាក់ព័ន្ធនឹងការសូកប៉ាន់ឬប្រព្រឹត្តមិនត្រឹមត្រូវ ឬការរំលោភអំណាច។
- មិនមែនជាមនុស្សអសមត្ថភាពផ្នែកស្មារតី

**អាស័យដ្ឋានប្រៃសណីយ៍**
រដ្ឋDelaware
ការិយាល័យគណៈកម្មការបោះឆ្នោតរដ្ឋ
905 S. Governors Ave., Suite 170
Dover, DE 19904

## រដ្ឋ District of Columbia

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី29 ខែតុលា ឆ្នាំ2003**

**កាលកំណត់ចុះឈ្មោះ** — 30 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** ច្បាប់សហព័ន្ធនាពេលបច្ចុប្បន្នតម្រូវឲ្យពាក្យស្នើសុំចុះឈ្មោះអ្នកបោះឆ្នោតទាំងអស់ត្រូវមានលេខប័ណ្ណបើកបរ ឬលេខសន្តិសុខសង្គមបួនខ្ទង់ចុងក្រោយរបស់អ្នកដាក់ពាក្យស្នើសុំដើម្បីដំណើរការ។
**7។ ជម្រើសបក្ស។** អ្នកត្រូវចុះឈ្មោះជាមួយបក្សប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬអនុសញ្ញា។
**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងស្រុកកូឡំបៀ អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- ជាពលរដ្ឋដែលស្នាក់នៅក្នុងស្រុកកូឡំបៀយ៉ាងតិច 30 ថ្ងៃមុនថ្ងៃបោះឆ្នោតបន្ទាប់
- មានអាយុយ៉ាងតិច 18 ឆ្នាំនៅថ្ងៃ ឬមុនការបោះឆ្នោតបន្ទាប់
- មិនជាប់ពន្ធនាគារពីបទឧក្រិដ្ឋ
- មិនត្រូវបានសម្រេចសេចក្តីថាជា “អសមត្ថភាពផ្នែកស្មារតី” ដោយតុលាការនាពេលថ្មីៗ
- មិនទាមទារសិទ្ធិបោះឆ្នោតនៅកន្លែងណាមួយក្រៅពី D.C

**អាស័យដ្ឋានប្រៃសណីយ៍**
ក្រុមប្រឹក្សាភិបាលស្រុកកូឡំបៀនៃការបោះឆ្នោត & សីលធម៌
ផ្លូវ 441 4th, NW, Suite 250
Washington, DC 20001-2745

## រដ្ឋ Florida

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី30 ខែវិច្ឆិកា ឆ្នាំ2011**

**កាលកំណត់ចុះឈ្មោះ** — 29 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ**
ប្រសិនបើអ្នកមានបណ្ណ អ្នកត្រូវផ្តល់លេខសម្គាល់ប័ណ្ណបើកបររដ្ឋ Florida ឬលេខអត្តសញ្ញាណប័ណ្ណរដ្ឋ Florida។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបររបស់រដ្ឋ Florida ឬអត្តសញ្ញាណប័ណ្ណទេ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ប្រសិនបើអ្នកមិនធ្លាប់ត្រូវចេញប័ណ្ណណាមួយឲ្យទេ អ្នកត្រូវសរសេរថា “គ្មាន”។
**7។ ជម្រើសបក្ស។** អ្នកត្រូវចុះឈ្មោះជាមួយបក្សប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬអនុសញ្ញា។
**8។ សាសន៍ ឬក្រុមជនជាតិ**
អ្នកត្រូវបានស្នើសុំ ប៉ុន្តែវាមិនចាំបាច់នោះទេ ក្នុងការបំពេញក្នុងប្រអប់នេះ។ សូមមើលបញ្ជីជម្រើសនៅក្នុងការណែនាំសម្រាប់ពាក្យស្នើសុំនៅប្រអប់ទី 8 (នៅទំព័រ 2)។
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Florida អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- ជាពលរដ្ឋស្នាក់នៅស្របច្បាប់ទាំងរដ្ឋ Floridaនិងខោនធីដែលអ្នកធ្វើការចុះឈ្មោះ
- មានអាយុ 18 ឆ្នាំ (អ្នកអាចចុះឈ្មោះឡើងវិញ ប្រសិនបើអ្នកមានអាយុយ៉ាងតិច 16 ឆ្នាំ)
- មិនត្រូវបានសម្រេចថាជាអសមត្ថជនផ្នែកស្មារតីពាក់ព័ន្ធនឹងការបោះឆ្នោតក្នុងរដ្ឋ Florida ឬរដ្ឋផ្សេងៗ ឬប្រសិនបើអ្នកមាន អ្នកត្រូវទទួលសម្បទានសិទ្ធិបោះឆ្នោតជាមុនសិន។
- មិនត្រូវបានផ្តន្ទាទោសឧក្រិដ្ឋ ឬប្រសិនបើអ្នកមានទោស អ្នកត្រូវបានផ្តល់សម្បទាសិទ្ធិពលរដ្ឋសិន ប្រសិនបើសិទ្ធិនេះត្រូវបានដក។
- ស្បថនិងបញ្ជាក់ដូចខាងក្រោម៖ “ខ្ញុំនឹងគោរពនិងការពាររដ្ឋធម្មនុញ្ញនៃសហរដ្ឋអាមេរិកនិងរដ្ឋធម្មនុញ្ញនៃរដ្ឋ Florida ថាខ្ញុំមានគុណវុឌ្ឍិគ្រប់គ្រាន់ក្នុងការចុះឈ្មោះជាអ្នកបោះឆ្នោតស្របតាមរដ្ឋធម្មនុញ្ញនិងច្បាប់នៃរដ្ឋ Florida និងរាល់ព័ត៌មានក្នុងពាក្យស្នើសុំនេះគឺត្រឹមត្រូវ។”

**អាស័យដ្ឋានប្រៃសណីយ៍**
រដ្ឋ Florida
ក្រសួងការបរទេស
ផ្នែករៀបចំការបោះឆ្នោត
The R.A. Gray Building
500 South Bronough St, Rm 316
Tallahassee, Florida 32399-0250

## រដ្ឋ Georgia

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី15 ខែសីហា ឆ្នាំ2013**

**កាលកំណត់ចុះឈ្មោះ** — ថ្ងៃច័ន្ទទីប្រាំមុនការបោះឆ្នោតបឋម ឬបោះឆ្នោតសកល ឬការបោះឆ្នោតពេញចិត្តបេក្ខភាពប្រធានាធិបតី ឬការបោះឆ្នោតពិសេសតាមកាលវិភាគទៀងទាត់ស្របតាមក្រមបោះឆ្នោតនៃរដ្ឋ Georgia។ ក្នុងករណីដែលការបោះឆ្នោតពិសេសត្រូវបានរៀបចំឡើងនៅកាលបរិច្ឆេទមួយផ្សេងដែលកាលបរិច្ឆេទនោះត្រូវបានកំណត់ដោយក្រមបោះឆ្នោតនៃរដ្ឋ Georgia ការចុះឈ្មោះត្រូវបិទនៅថ្ងៃទី 5 ក្រៅពីការអំពាវនាវ។

**6។ លេខអត្តសញ្ញាណបណ្ណ** ច្បាប់សហពន្ធតម្រូវឲ្យអ្នកផ្តល់លេខបណ្ណបើកបរ GA ពេញរបស់អ្នក ឬលេខអត្តសញ្ញាណប័ណ្ណដែលចេញដោយរដ្ឋ GA របស់អ្នក។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបររបស់ GA ឬអត្តសញ្ញាណប័ណ្ណទេ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ការផ្តល់លេខសន្តិសុខសង្គមពេញរបស់អ្នកគឺជាជម្រើសប៉ុណ្ណោះ។ លេខសន្តិសុខសង្គមរបស់អ្នកត្រូវរក្សាការសម្ងាត់ និងអាចត្រូវបានប្រើសម្រាប់ប្រៀបធៀបជាមួយទិន្នន័យភ្នាក់ងាររដ្ឋផ្សេងៗសម្រាប់គោលបំណងបញ្ជាក់អត្តសញ្ញាណចុះឈ្មោះអ្នកបោះឆ្នោត។ ប្រសិនបើអ្នកមិនមានលេខប័ណ្ណបើកបរ ឬលេខសន្តិសុខសង្គមទេ លេខបញ្ជាក់អត្តសញ្ញាណមួយនឹងផ្តល់ឲ្យអ្នក។
**7។ ជម្រើសបក្ស។** អ្នកមិនចាំបាច់ត្រូវតែចុះឈ្មោះជាមួយបក្សទេក្នុងការចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬសមាជ។

**8។ សាសន៍ ឬក្រុមជនជាតិ** អ្នកត្រូវបានស្នើសុំក្នុងការបំពេញក្នុងប្រអប់នេះ។ សូមមើលបញ្ជីជម្រើសនៅក្នុងការណែនាំសម្រាប់ពាក្យស្នើសុំនៅប្រអប់ទី 8 (នៅទំព័រ 2)។
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Georgia អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- ស្នាក់នៅស្របច្បាប់ក្នុងរដ្ឋ Georgiaនិងខោនធីដែលអ្នកចង់បោះឆ្នោត
- មានអាយុ 18 ឆ្នាំក្នុងអំឡុងពេលប្រាំមួយខែក្រោយថ្ងៃចុះឈ្មោះ និងមានអាយុ 18 ឆ្នាំដើម្បីបោះឆ្នោត
- មិនត្រូវផ្តន្ទាទោសពីការប្រព្រឹត្តបទឧក្រិដ្ឋ
- មិនត្រូវបានសម្រេចដោយតុលាការថាជាអសមត្ថជនផ្នែកស្មារតី លើកលែងតែពិការភាពនេះត្រូវបានដកចេញ

**អាស័យដ្ឋានប្រៃសណីយ៍**
ផ្នែកការបោះឆ្នោត
ការិយាល័យលេខាធិការរដ្ឋ
2 Martin Luther King Jr. Drive
Suite 802 Floyd West Tower
Atlanta, Georgia 30334

## រដ្ឋ Hawaii

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ** — 30 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** លេខសន្តិសុខសង្គមពេញរបស់អ្នកគឺជាតម្រូវការចាំបាច់។ វាត្រូវបានប្រើដើម្បីការពារការចុះឈ្មោះបន្លំ និងការបោះឆ្នោត។ ការខកខានក្នុងការផ្តល់ព័ត៌មាននេះនឹងត្រូវរារាំងការទទួលយកពាក្យស្នើសុំនេះ (ច្បាប់កែសម្រួលរដ្ឋហាវ៉ៃ ផ្នែកទ 11-15)។
**7។ ជម្រើសបក្ស។** "ជម្រើសបក្ស" មិនត្រូវបានតម្រូវសម្រាប់ការចុះឈ្មោះបោះឆ្នោតទេ។
**8។ សាសន៍ ឬក្រុមជនជាតិ** ព័ត៌មានអំពីសាសន៍ឬក្រុមជនជាតិមិនត្រូវបានតម្រូវសម្រាប់ការចុះឈ្មោះអ្នកបោះឆ្នោតទេ។
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Hawaii អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- ស្នាក់នៅក្នុងរដ្ឋ Hawaii
- មានអាយុយ៉ាងតិច 16 ឆ្នាំ (អ្នកត្រូវមានអាយុ 18ឆ្នាំនៅថ្ងៃបោះឆ្នោតដើម្បីអាចបោះឆ្នោត)
- មិនត្រូវជាប់ពន្ធនាគារពីបទឧក្រិដ្ឋណាមួយ
- មិនត្រូវសម្រេចដោយតុលាការថា "មិនមានសតិគ្រប់គ្រាន់"

**អាស័យដ្ឋានប្រៃសណីយ៍**
ការិយាល័យបោះឆ្នោត
រដ្ឋ Hawaii
802 Lehua Avenue
Pearl City, HI 96782

## រដ្ឋ Idaho

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ** — 25 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ**
សូមបញ្ចូលលេខប័ណ្ណបើកបររបស់អ្នក។ ប្រសិនបើអ្នកមិនមានបណ្ណបើកបរទេ ចូរបញ្ចូលលេខសន្តិសុខសង្គម បួនខ្ទង់ចុងក្រោយរបស់អ្នក។
**7។ ជម្រើសបក្ស។** អ្នកមិនចាំបាច់ត្រូវតែចុះឈ្មោះជាមួយបក្សទេ ប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬសមាជ។
**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Idaho អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- មានលំនៅស្ថាននៅរដ្ឋ Idaho និងក្នុងខោនធីរយៈ 30 ថ្ងៃមុនថ្ងៃបោះឆ្នោត
- មានអាយុយ៉ាងតិច 18 ឆ្នាំ
- មិនត្រូវបានផ្តន្ទាទោសឧក្រិដ្ឋ និងមិនត្រូវបានផ្តល់សម្បទាសិទ្ធិជាពលរដ្ឋឡើងវិញ ឬជាប់ពន្ធនាគារនៃបទល្មើសព្រហ្មទណ្ឌ

**អាស័យដ្ឋានប្រៃសណីយ៍**
រដ្ឋមន្ត្រី
P.O. ប្រអប់ 83720
State Capitol Bldg.
Boise, ID 83720-0080

## រដ្ឋ Illinois

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី14 ខែសីហា ឆ្នាំ2012**

**កាលកំណត់ចុះឈ្មោះ** — 28 ថ្ងៃមុនការបោះឆ្នោតនីមួយៗ។

**6។ លេខអត្តសញ្ញាណបណ្ណ** លេខប័ណ្ណបើកបររបស់អ្នកត្រូវបានតម្រូវចំពោះអ្នកចុះបញ្ជីដើម្បីបោះឆ្នោត។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបរទេ យ៉ាងហោចណាស់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នកត្រូវផ្តល់ជូន។ ប្រសិនបើអ្នកមិនមានលេខណាមួយទេ សូមសរសេរ "គ្មាន" នៅលើទម្រង់នេះ។ លេខសម្គាល់មួយនឹងត្រូវចេញឲ្យអ្នកដោយរដ្ឋ។
**7។ ជម្រើសបក្ស។** ការចុះឈ្មោះគណៈបក្សឬការពេញចិត្តបក្សមិនតម្រូវសម្រាប់ការចុះឈ្មោះអ្នកបោះឆ្នោតទេ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអ្នកដាក់សន្លឹកឆ្នោតដំបូង អ្នកត្រូវបង្ហាញការពេញចិត្តសម្រាប់ការបោះឆ្នោតនោះ។
**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ
**9។ ហត្ថលេខា។** ហត្ថលេខាតម្រូវជាចាំបាច់។ ប្រសិនបើមិនមានហត្ថលេខានៅលើទម្រង់ពាក្យស្នើសុំទេ អ្នកនឹងត្រូវជូនដំណឹងថាពាក្យស្នើសុំរបស់អ្នកមិនពេញលេញទេ។
ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Illinois អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- មានលំនៅស្ថាននៅរដ្ឋ Illinois និងដែលជាកន្លែងបោះឆ្នោតរបស់អ្នក យ៉ាងតិច 30 ថ្ងៃមុនការបោះឆ្នោតបន្ទាប់
- មានអាយុយ៉ាងតិច 18 ឆ្នាំនៅថ្ងៃ ឬមុនថ្ងៃការបោះឆ្នោតបន្ទាប់
- មិនជាប់ពន្ធនាគារពីបទឧក្រិដ្ឋ
- មិនទាមទារសិទ្ធិបោះឆ្នោតនៅកន្លែងផ្សេងទៀត

**អាស័យដ្ឋានប្រៃសណីយ៍**
ក្រុមប្រឹក្សារដ្ឋនៃការបោះឆ្នោត
2329 S. MacArthur Boulevard
Springfield, IL 62704

## រដ្ឋ Indiana

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ** — 29 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** លេខអត្តសញ្ញាណប័ណ្ណអ្នកបោះឆ្នោតរដ្ឋរបស់អ្នកគឺជាលេខប័ណ្ណបើកបរដែលចេញដោយរដ្ឋ Indiana ដែលមានដប់ខ្ទង់របស់អ្នក។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបររបស់រដ្ឋ Indiana ឬអត្តសញ្ញាណប័ណ្ណទេ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ សូមបង្ហាញលេខដែលអ្នកបានផ្តល់។ (ក្រមIndiana 3-7-13-13)
**7។ ជម្រើសបក្ស។** សូមទុកឲ្យនៅទំនេរ
**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Indiana អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- មានលំនៅស្ថានយ៉ាងតិច 30 ថ្ងៃមុនការបោះឆ្នោតបន្ទាប់
- មានអាយុយ៉ាងតិច 18 ឆ្នាំនៅថ្ងៃបោះឆ្នោតសកលបន្ទាប់
- មិនត្រូវជាប់ពន្ធនាគារពីបទឧក្រិដ្ឋនាពេលបច្ចុប្បន្ន

**អាស័យដ្ឋានប្រៃសណីយ៍**
ផ្នែកការបោះឆ្នោត
ការិយាល័យលេខាធិការរដ្ឋ
ផ្លូវ 302 West Washington
បន្ទប់ E-204
Indianapolis, IN 46204-2743

## រដ្ឋ Iowa

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី28 ខែមីនា ឆ្នាំ2008**

**កាលកំណត់ចុះឈ្មោះ —** ត្រូវបញ្ជូននៅម៉ោង 5 ល្ងាច 10 ថ្ងៃមុនការបោះឆ្នោត ប្រសិនបើវាគឺជាការបោះឆ្នោតបឋម ឬការបោះឆ្នោតទូទៅ និង 11 ថ្ងៃមុនសម្រាប់ការបោះឆ្នោតផ្សេងទៀត។* ទម្រង់ការចុះឈ្មោះដែលផ្ញើតាមប្រៃសណីយ៍ 15 ឬច្រើនថ្ងៃមុនការបោះឆ្នោត ត្រូវគិតថាមកដល់ទាន់ពេលវេលាប្រសិនបើវាទទួលបានក្រោយកាលកំណត់ក្តី។

*ប្រសិនបើអ្នកខកខានតាមកាលកំណត់ចុះឈ្មោះអ្នកបោះឆ្នោតខាងលើ អ្នកអាចចុះឈ្មោះបោះឆ្នោតតាមរយៈការណែនាំសម្រាប់ការចុះឈ្មោះថ្ងៃបោះឆ្នោតខាងក្រោម។ អ្នកអាចស្វែងរកការណែនាំទាំងនេះនៅលើគេហទំព័ររបស់រដ្ឋមន្ត្រី www.sos.state.ia.us/pdfs/elections/EDRbrochure.pdf.

**6។ លេខអត្តសញ្ញាណបណ្ណ** លេខអត្តសញ្ញារបស់អ្នកគឺលេខប័ណ្ណបើកបរដែលចេញដោយរដ្ឋ Iowa របស់អ្នក (ឬលេខបណ្ណបញ្ជាក់អត្តសញ្ញាណមិនបើកបរ) ប្រសិនបើអ្នកមានណាមួយ។ ប្រសិនបើអ្នកមិនមាន ត្រូវផ្តល់លេខបួនខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ លេខអត្តសញ្ញាណដែលអ្នកផ្តល់ឲ្យនឹងត្រូវបញ្ជាក់ដោយក្រសួងដឹកជញ្ជូនរដ្ឋ Iowa ឬរដ្ឋបាលសន្តិសុខសង្គម។

**7។ ជម្រើសបក្ស។** អ្នកអាចចុះឈ្មោះជាមួយបក្សណាមួយជាមុន ប្រសិនបើអ្នកចង់ចូលរួម នៅក្នុងការបោះឆ្នោតបឋម តែវាមិនមែនជាករណីចាំបាច់ទេ។ អ្នកអាចប្តូរ ឬប្រកាសអំពីសម្ព័ន្ធភាពបក្សនៅការិយាល័យបោះឆ្នោតនៅថ្ងៃបោះឆ្នោតបឋមក៏បាន។

**8។ សាសន៍ ឬក្រុមជនជាតិ** សូមទុកឲ្យនៅទំនេរ

**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Iowa អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- មានលំនៅនៅរដ្ឋ Iowa
- មានអាយុយ៉ាងតិច 17 ឆ្នាំកន្លះ (អ្នកត្រូវមានអាយុ 18 ឆ្នាំដើម្បីអាចបោះឆ្នោត)
- មិនត្រូវបានផ្តន្ទាទោសឧក្រិដ្ឋ (ឬបានទទួលសិទ្ធិពលរដ្ឋឡើងវិញ)
- មិនត្រូវបានសម្រេចសេចក្តីថា "ជាអសមត្ថភាពក្នុងការបោះឆ្នោត" ដោយតុលាការនាពេលថ្មីៗ
- មិនទាមទារសិទ្ធិបោះឆ្នោតច្រើនជាងមួយកន្លែង
- ត្រូវបោះបង់សិទ្ធិបោះឆ្នោតនៅកន្លែងផ្សេងទៀត

**អាស័យដ្ឋានប្រៃសណីយ៍**
ផ្នែកការបោះឆ្នោត
ការិយាល័យលេខាធិការរដ្ឋ
អាគារ Lucas Building-ជាន់ទី 1
321 E. ផ្លូវទី 12
Des Moines, IA 50319

## រដ្ឋ Kansas

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី25 ខែសីហា ឆ្នាំ2013**

**កាលកំណត់ចុះឈ្មោះ —** ផ្ញើតាមប្រៃសណីយ៍ ឬប្រគល់ 21 ថ្ងៃមុនការបោះឆ្នោត

**6។ លេខអត្តសញ្ញាណបណ្ណ** ទម្រង់ចុះឈ្មោះបោះឆ្នោតរបស់អ្នកត្រូវមានលេខបណ្ណបើកបរដែលចេញដោយរដ្ឋ ឬលេខអត្តសញ្ញាណមិនប្រតិបត្តិការរបស់អ្នក។ ប្រសិនបើអ្នកមិនមានបណ្ណបើកបរ ឬអត្តសញ្ញាណបណ្ណមិនបើកបរទេ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ប្រសិនបើអ្នកមិនមានបណ្ណបើកបរ ឬ បណ្ណបញ្ជាក់មិនប្រតិបត្តិការ ឬលេខសន្តិសុខសង្គមទេ ចូរសរសេរ "គ្មាន" នៅលើទម្រង់នេះ។ លេខសម្គាល់មួយនឹងត្រូវចេញឲ្យអ្នកដោយរដ្ឋ។ លេខដែលអ្នកផ្តល់ នឹងត្រូវប្រើសម្រាប់គោលបំណងរដ្ឋបាលប៉ុណ្ណោះនិងមិនត្រូវបង្ហាញជាសាធារណៈឡើយ។ (KSA 25-2309)។

**7។ ជម្រើសបក្ស។** អ្នកត្រូវចុះឈ្មោះជាមួយបក្សប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬអនុសញ្ញា។

**8។ សាសន៍ ឬក្រុមជនជាតិ** សូមទុកឲ្យនៅទំនេរ

**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Kansas អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- មានលំនៅនៅរដ្ឋ Kansas
- មានអាយុ 18 ឆ្នាំនៅការបោះឆ្នោតបន្ទាប់
- បានបញ្ចប់រយៈពេលអនុវត្តទោស ប្រសិនបើអ្នកត្រូវបានផ្តន្ទាទោសឧក្រិដ្ឋ។ បុគ្គលដែលកំពុងអនុវត្តទោសឧក្រិដ្ឋមិនមានសិទ្ធិបោះឆ្នោតទេ
- មិនទាមទាសិទ្ធិបោះឆ្នោតនៅទីតាំងផ្សេង ឬដោយប្រើឈ្មោះផ្សេង
- មិនត្រូវបានដកសិទ្ធិបោះឆ្នោតដោយតុលាការមានសមត្ថកិច្ច

**អាស័យដ្ឋានប្រៃសណីយ៍**
រដ្ឋមន្ត្រី
ជាន់ទី 1 សាល Memorial
120 SW 10th Ave.
Topeka, KS 66612-1594

## រដ្ឋ Kentucky

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ —** 29 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** លេខសន្តិសុខសង្គមពេញរបស់អ្នកគឺជាតម្រូវការចាំបាច់។ វាត្រូវបានប្រើសម្រាប់គោលបំណងរដ្ឋបាលប៉ុណ្ណោះ និងមិនត្រូវផ្សព្វផ្សាយជាសាធារណៈទេ (KRS 116.155)។ គ្មានបុគ្គលណាមួយត្រូវបានបដិសេធសិទ្ធិចុះឈ្មោះបោះឆ្នោតដោយមូលហេតុនៃការខកខានបង្ហាញលេខសន្តិសុខសង្គមឡើយ។

**7។ ជម្រើសបក្ស។** អ្នកត្រូវចុះឈ្មោះជាមួយបក្សប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬអនុសញ្ញា។

**8។ សាសន៍ ឬក្រុមជនជាតិ** សូមទុកឲ្យនៅទំនេរ

**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Kentucky អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- មានលំនៅនៅរដ្ឋ Kentucky
- មានលំនៅស្ថាននៅក្នុងខោនធីយ៉ាងតិច 28 ថ្ងៃមុនកាលបរិច្ឆេទនៃការបោះឆ្នោត
- មានអាយុ 18 ឆ្នាំនៅថ្ងៃ ឬមុនការបោះឆ្នោតបន្ទាប់
- មិនត្រូវបានផ្តន្ទាទោសជាទណ្ឌិត ឬប្រសិនបើមានការផ្តន្ទាទោសឧក្រិដ្ឋ សិទ្ធិពលរដ្ឋរបស់អ្នកត្រូវបានផ្តល់ឡើងវិញដោយការលើកលែងទោស
- មិនត្រូវបានសម្រេចសេចក្តីថាជា "មនុស្សអសមត្ថភាពផ្នែកស្មារតី" ដោយតុលាការ

• មិនទាមទារសិទ្ធិបោះឆ្នោតនៅកន្លែងណាមួយក្រៅពីរដ្ឋ Kentucky

**អាស័យដ្ឋានប្រៃសណីយ៍**
ក្រុមប្រឹក្សារដ្ឋនៃការបោះឆ្នោត
ផ្លូវ 140 Walnut
Frankfort, KY 40601-3240

## រដ្ឋ Louisiana

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី14 ខែសីហា ឆ្នាំ2012**

**កាលកំណត់ចុះឈ្មោះ —** 30 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** អ្នកត្រូវផ្តល់លេខប័ណ្ណបើកបរនៃរដ្ឋ Louisiana របស់អ្នក ឬលេខអត្តសញ្ញាណប័ណ្ណពិសេសនៃរដ្ឋ Louisiana បើមាន។ ប្រសិនមិនមានទេ អ្នកត្រូវផ្តល់លេខសន្តិសុខសង្គមបួនខ្ទង់ចុងក្រោយរបស់អ្នក ដែលបានផ្តល់ឲ្យ។ ការផ្តល់លេខសន្តិសុខសង្គមពេញអាចត្រូវបានផ្តល់តែដោយការស្ម័គ្រចិត្តប៉ុណ្ណោះ។ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំមិនមានទាំងប័ណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណពិសេស ឬលេខសន្តិសុខសង្គម អ្នកដាក់ពាក្យស្នើសុំត្រូវភ្ជាប់ឯកសារណាមួយដូចខាងក្រោមជាមួយពាក្យស្នើសុំរបស់ខ្លួន៖ (ក) ឯកសារថតចម្លងរូបភាពមានសុពលភាពនិងបច្ចុប្បន្ន ឬ (ខ) ឯកសារថតចម្លងវិក្កយបត្រប្រើប្រាស់ របាយការណ៍ធនាគារ សែករដ្ឋាភិបាល បណ្ណទូទាត់ ឬឯកសាររដ្ឋាភិបាលផ្សេងទៀត ដែលមានឈ្មោះនិងអាសយដ្ឋានរបស់អ្នកដាក់ពាក្យស្នើសុំ។ ទាំងមន្ត្រីអគ្រានុកូលដ្ឋាននិងក្រសួងការបរទេសមិនត្រូវបង្ហាញលេខសន្តិសុខសង្គមរបស់អ្នកចុះឈ្មោះបោះឆ្នោត ឬផ្តល់លេខសន្តិសុខសង្គមរបស់អ្នកចុះឈ្មោះបោះឆ្នោតទៅបញ្ជីពាណិជ្ជកម្ម (R.S. 18:104 and 154; 42 U.S.C. § 405)។

**7។ ជម្រើសបក្ស។** ប្រសិនបើអ្នកចុះបញ្ជីសម្ព័ន្ធគណៈបក្សនយោបាយ អ្នកមិនអាចបោះឆ្នោតពេញចិត្តបេក្ខភាពប្រធានាធិបតី និងការបោះឆ្នោតគណកម្មការបក្សបានទេ។ សម្ព័ន្ធភាពបក្សនយោបាយមិនមែនជាការតម្រូវសម្រាប់ការបោះឆ្នោតផ្សេងៗទេ។

**8។ សាសន៍ ឬក្រុមជនជាតិ** អ្នកត្រូវបានស្នើសក្នុងការបំពេញក្នុងប្រអប់នេះ។ សូមមើលបញ្ជីជម្រើសនៅក្នុងការណែនាំសម្រាប់ពាក្យស្នើសុំនៅប្រអប់ទី 8 (នៅទំព័រ 2)។

**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Louisiana អ្នកត្រូវ៖

• ជាពលរដ្ឋសហរដ្ឋអាមេរិក
• មានលំនៅស្ថាននៅរដ្ឋ Louisiana (អាស័យដ្ឋានត្រូវតែជាអាស័យដ្ឋានដែលអ្នកទាមទារការលើកលែងលក្ខខ័ណ្ឌគ្រួសារ បើមានលើកលែងចំពោះលំនៅស្ថានថែទាំ ឬលំនៅស្ថានអតីតយុវជនដែលអាចជ្រើសប្រើជាអាសយដ្ឋាននៃការថែទាំនិងអតីតយុវជន ឬលំនៅស្ថានដែលគាត់មានជាលក្ខណគ្រួសារ។ និស្សិតមហាវិទ្យាល័យអាចជ្រើសប្រើអាសយដ្ឋាននេះ ឬអាសយដ្ឋានផ្ទាល់ខ្លួននៅពេលនៅឆ្ងាយពីសាលា។)
• មានអាយុយ៉ាងតិច 17 ឆ្នាំ និងមានអាយុ 18 ឆ្នាំមុនពេលបោះឆ្នោតបន្ទាប់
• មិនត្រូវស្ថិតនៅក្រោមដីកាជាប់ពន្ធនាគារសម្រាប់បទឧក្រិដ្ឋ
• មិនត្រូវស្ថិតក្រោមសាលក្រមកំណត់ពីអសមត្ថភាពផ្នែកស្មារតី

**អាស័យដ្ឋានប្រៃសណីយ៍**
រដ្ឋមន្ត្រី
ការប្រុងប្រយ័ត្ន៖
ការចុះឈ្មោះអ្នកបោះឆ្នោត
P.O. ប្រអប់ 94125
Baton Rouge, LA 70804-9125

## រដ្ឋ Maine

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី14 ខែសីហា ឆ្នាំ2012**

**កាលកំណត់ការចុះឈ្មោះ —** ត្រូវបាផ្តល់ជូន 21 ថ្ងៃធ្វើការមុនការបោះឆ្នោត((ឬអ្នកបោះឆ្នោតអាចចុះឈ្មោះ *ដោយផ្ទាល់* រហូតដល់ថ្ងៃបោះឆ្នោត)៕

**6។ លេខអត្តសញ្ញាណបណ្ណ** អ្នកត្រូវសរសេរលេខប័ណ្ណបើកបរមានសុពលភាពនៃរដ្ឋ Maine របស់អ្នក។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបរមានសុពលភាពនៃរដ្ឋ Maine ទេ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ អ្នកបោះឆ្នោតដែលមិនមានឯកសារទាំងនេះត្រូវសរសេរ “គ្មាន” នៅក្នុងចន្លោះនេះ។

**7។ ជម្រើសបក្ស។** អ្នកត្រូវចុះឈ្មោះជាមួយបក្សប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬអនុសញ្ញា (លើកលែងតែត្រូវបានកំណត់ផ្សេងដោយបក្សនយោបាយ)។

**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ

**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Maine អ្នកត្រូវ៖

• ជាពលរដ្ឋសហរដ្ឋអាមេរិក
• មានលំនៅស្ថាននៅរដ្ឋ Maineនិងក្រុងដែលអ្នកចង់ បោះឆ្នោត។
• មានអាយុយ៉ាងតិច 17 ឆ្នាំ((អ្នកត្រូវមានអាយុ 18 ឆ្នាំដើម្បីអាចបោះឆ្នោត)

**អាស័យដ្ឋានប្រៃសណីយ៍**
ផ្នែកការបោះឆ្នោត
ការិយាល័យគណៈកម្មការ
ការបោះឆ្នោតនិងគណៈកម្មការ
101 State House Station
Augusta, ME 04333-0101

## រដ្ឋ Maryland

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី26 ខែមិថុនា ឆ្នាំ2008**

**កាលកំណត់ចុះឈ្មោះ —** 9:00 យប់ 21 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** ប្រសិនបើអ្នកមានប័ណ្ណបើកបរមានសុពលភាពនិងបច្ចុប្បន្ននៃរដ្ឋ Maryland ឬប័ណ្ណរដ្ឋបាលទោចក្រយានយន្ត អ្នកត្រូវបញ្ចូលលេខអត្តសញ្ញាណឬប័ណ្ណបើកបរណាមួយ។ ប្រសិនបើអ្នកមានប័ណ្ណបើកបរមានសុពលភាពនិងបច្ចុប្បន្ននៃរដ្ឋ Maryland ឬប័ណ្ណរដ្ឋបាលទោចក្រយានយន្ត អ្នកត្រូវបញ្ចូលលេខបួនខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ទោះបីជាយ៉ាងនេះក្តី សូមសម្គាល់ថា ការបង្ហាញលេខសន្តិសុខសង្គមពេញគឺឈរលើមូលដ្ឋានស្ម័គ្រចិត្ត។ អាជ្ញាធរជម្មានរូបអនុញ្ញាតមន្ត្រីបោះឆ្នោតស្នើសុំលេខសន្តិសុខពេញរបស់អ្នក គឺមាត្រានៃច្បាប់បោះឆ្នោតផ្នែក 3-202 កំណត់បង្ហាញក្រមនៃរដ្ឋ Maryland។ លេខនេះនឹងត្រូវប្រើប្រាស់សម្រាប់តែគោលបំណងចុះឈ្មោះនិងគោលបំណងរដ្ឋបាលប៉ុណ្ណោះផ្សេងៗប៉ុណ្ណោះ៕ព័ត៌មាននេះនឹងត្រូវទុកជាការសម្ងាត់។

**7។ ជម្រើសបក្ស។** អ្នកត្រូវចុះឈ្មោះជាមួយបក្សប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ។
**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Maryland អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- ស្នាក់នៅក្នុងរដ្ឋ Maryland
- មានអាយុយ៉ាងតិច 18 ឆ្នាំត្រឹមថ្ងៃបោះឆ្នោតសកលបន្ទាប់
- មិនស្ថិតក្រោមអាណាព្យាបាលសម្រាប់អសមត្ថភាពផ្នែកស្មារតី
- មិនត្រូវបានផ្តន្ទាទោសនៃការទិញឬលក់សន្លឹកឆ្នោត
- មិនត្រូវបានផ្តន្ទាទោសបទឧក្រិដ្ឋ ឬប្រសិនបើអ្នកមាន អ្នកបានអនុវត្តទោសជាប់ពន្ធនាគាររួចហើយ រួមទាំងការឃុំខ្លួន ឬការបង្ខាំងខ្លួន។

**អាស័យដ្ឋានប្រៃសណីយ៍**
ក្រុមប្រឹក្សារដ្ឋនៃការបោះឆ្នោត
P.O. ប្រអប់ 6486
Annapolis, MD 21401-0486

## រដ្ឋ Massachusetts

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ** — 20 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** ច្បាប់សហព័ន្ធតម្រូវថាអ្នកត្រូវផ្តល់លេខប័ណ្ណបើកបររបស់អ្នកដើម្បីចុះឈ្មោះបោះឆ្នោត។ ប្រសិនបើអ្នកមិនមានបណ្ណបើកបរមានសុពលភាពនៃរដ្ឋMassachusetts ទេ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ប្រសិនបើអ្នកមិនមានឯកនេះទេ អ្នកត្រូវសរសេរ "គ្មាន" នៅក្នុងប្រអប់នេះ ហើយលេខសម្គាល់មួយនឹងត្រូវផ្តល់ឲ្យអ្នក។
**7។ ជម្រើសបក្ស។** ប្រសិនបើអ្នកមិនកំណត់នូវបក្សនយោបាយនៅក្នុងប្រអប់នេះ អ្នកនឹងត្រូវចុះឈ្មោះជាមិនទាន់បានចុះ។ អ្នកបោះឆ្នោតមិនបានចុះឈ្មោះអាចចូលរួមក្នុងការបោះឆ្នោតបក្សបឋមបាន។ ប៉ុន្តែ អ្នកបោះឆ្នោតមិនបានចុះឈ្មោះត្រូវចុះឈ្មោះបក្សនៅថ្ងៃបោះឆ្នោតពេញចិត្តបេក្ខភាពប្រធានាធិបតីដើម្បីចូលរួមក្នុងការបោះឆ្នោតនោះ។
**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Massachusetts អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- មានលំនៅស្ថាននៅក្នុងរដ្ឋ Massachusetts
- មានអាយុ 18 ឆ្នាំនៅថ្ងៃ ឬមុនថ្ងៃការបោះឆ្នោតបន្ទាប់
- មិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទពុករលួយពាក់ព័ន្ធនឹងការបោះឆ្នោត
- មិនស្ថិតក្រោមរបបអាណាព្យាបាលពាក់ព័ន្ធនឹងការបោះឆ្នោត
- មិនត្រូវជាប់ពន្ធនាគារពីបទឧក្រិដ្ឋ

**អាស័យដ្ឋានប្រៃសណីយ៍**
រដ្ឋមន្ត្រីនៃ Commonwealth
ផ្នែកការបោះឆ្នោត បន្ទប់ 1705
One Ashburton Place
Boston, MA 02108

## រដ្ឋ Michigan

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ** — 30 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** ទម្រង់ចុះឈ្មោះបោះឆ្នោតរបស់អ្នកត្រូវមានលេខប័ណ្ណបើកបរដែលចេញដោយរដ្ឋ ឬលេខអត្តសញ្ញាណប័ណ្ណបុគ្គលដែលចេញដោយរដ្ឋរបស់អ្នក។ ប្រសិនបើអ្នកមិនមានបណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណផ្ទាល់ខ្លួនទេ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ប្រសិនបើអ្នកមិនមានបណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណផ្ទាល់ខ្លួនចេញដោយរដ្ឋ ឬលេខសន្តិសុខសង្គមទេ ចូរសរសេរ "គ្មាន" នៅលើទម្រង់នេះ។ លេខសម្គាល់មួយនឹងត្រូវចេញឲ្យអ្នកដោយរដ្ឋ។
**7។ ជម្រើសបក្ស។** "ជម្រើសបក្ស" គឺមិនតម្រូវចាំបាច់សម្រាប់ការចុះឈ្មោះអ្នកបោះឆ្នោតទេ។
**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Michigan អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- មានអាយុ 18 ឆ្នាំត្រឹមថ្ងៃការបោះឆ្នោតបន្ទាប់
- មានលំនៅស្ថាននៅរដ្ឋ Michigan និងស្នាក់នៅយ៉ាងតិច 30 ថ្ងៃក្នុងទីក្រុង ឬស្រុករបស់អ្នកត្រឹមថ្ងៃបោះឆ្នោត
- មិនត្រូវបានផ្តន្ទាទោសជាប់ពន្ធនាគារក្រោយពីការដាក់ទោស

***សម្គាល់៖*** ច្បាប់រដ្ឋ Michigan តម្រូវថា អាស័យដ្ឋានដូចគ្នាត្រូវបានប្រើសម្រាប់ការចុះឈ្មោះបោះឆ្នោតនិងគោលបំណងប័ណ្ណបើកបរ។ ដូច្នេះ ប្រសិនបើអាសយដ្ឋានស្នាក់នៅដែលអ្នកផ្តល់ក្នុងទម្រង់នេះខុសគ្នាពីអាសយដ្ឋាននៅលើប័ណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណផ្ទាល់ខ្លួនដែលចេញដោយរដ្ឋ Michigan រដ្ឋមន្ត្រីនឹងធ្វើការប្តូរអាសយដ្ឋានប័ណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណរបស់អ្នកឲ្យដូចគ្នាអាស័យដ្ឋានដែលអ្នកបានបំពេញក្នុងទម្រង់នេះដោយស្វ័យប្រវត្តិ។ ប្រសិនបើអាស័យដ្ឋានត្រូវបានប្តូរ រដ្ឋមន្ត្រីនឹងផ្ញើឲ្យអ្នកនូវលិខិតស្តីពីការធ្វើបច្ចុប្បន្នភាពអាស័យដ្ឋានសម្រាប់ប័ណ្ណបើកបរឬអត្តសញ្ញាណប័ណ្ណផ្ទាល់ខ្លួនរបស់អ្នក។
**ការប្រុងប្រយ័ត្ន៖** ប្រសិនបើអ្នកចុះឈ្មោះតាមរយៈផ្ញើប្រៃសណីយ៍ អ្នកត្រូវមកបោះឆ្នោតនៅទីតាំងរបស់អ្នកនៅលើកដំបូងដែលអ្នកបោះឆ្នោត លើកលែងតែអ្នកគឺ៖
- ជាជនពិកាតាមការកំណត់ដោយច្បាប់
- មានអាយុ 60 ឆ្នាំ ឬច្រើនជាង ឬ
- ស្នាក់នៅជាបណ្តោះអាសន្ននៅក្រៅប្រទេស។

**អាស័យដ្ឋានប្រៃសណីយ៍**
ក្រសួងការបរទេសនៃរដ្ឋ Michigan
ការិយាល័យបោះឆ្នោត
P.O. ប្រអប់ 20126
Lansing, MI 48901-0726

## រដ្ឋ Minnesota

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2008**

**កាលកំណត់ចុះឈ្មោះ** — ត្រូវបញ្ជូននៅម៉ោង 5:00 ល្ងាច 21 ថ្ងៃមុនថ្ងៃបោះ (ក៏មានការចុះឈ្មោះនៅថ្ងៃបោះឆ្នោតផងដែរនៅមណ្ឌលបោះឆ្នោត)។

**6។ លេខអត្តសញ្ញាណបណ្ណ** អ្នកត្រូវផ្តល់លេខប័ណ្ណបើកបរនៃរដ្ឋ Minnesota ឬលេខអត្តសញ្ញានប័ណ្ណរដ្ឋដើម្បីចុះឈ្មោះបោះឆ្នោត។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណរដ្ឋ Minnesota

ទេ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ប្រសិនបើអ្នកមិនមានលេខណាមួយទេ សូមសរសេរ "គ្មាន" នៅលើទម្រង់នេះ។
**7។ ជម្រើសបក្ស។** សូមទុកឲ្យនៅទំនេរ។
**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ។
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Minnesota អ្នកត្រូវ៖
• ជាពលរដ្ឋសហរដ្ឋអាមេរិក
• មានលំនៅស្ថាននៅរដ្ឋ Minnesota 20 ថ្ងៃមុនការបោះឆ្នោតបន្ទាប់
• នៅរក្សាលំនៅស្ថានតាមអាស័យដ្ឋានដែលបានផ្តល់នៅលើទម្រង់នេះ
• មានអាយុយ៉ាងតិច 18 ឆ្នាំនៅថ្ងៃបោះឆ្នោត
• ប្រសិនបើធ្លាប់ត្រូវផ្តន្ទាទោសឧក្រិដ្ឋ ទោសនេះត្រូវផុត ឬអនុវត្តរួចរាល់ ឬអ្នកត្រូវបានទម្លាក់ចោលរាល់ទោសទាំងឡាយ
• មិនស្ថិតក្រោមដីកាតុលាការក្រោមអាណាព្យាបាលដែលសិទ្ធិបោះឆ្នោតត្រូវបានដកហូត
• មិនត្រូវបានសម្រេចដោយតុលាការថាជាមនុស្សអសមត្ថភាពផ្លូវច្បាប់ក្នុងការបោះឆ្នោត

**អាស័យដ្ឋានប្រៃសណីយ៍**
រដ្ឋមន្រ្តី
60 Empire Drive, Suite 100
St. Paul, MN 55103-1855

## រដ្ឋ Mississippi

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី07 ខែឧសភា ឆ្នាំ2010**

**កាលកំណត់ចុះឈ្មោះ** — 30 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** អ្នកត្រូវបានតម្រូវឲ្យផ្តល់លេខបណ្ណបើកបរបច្ចុប្បន្ននិងមានសុពលភាព ឬប្រសិនបើអ្នកមិនមានទេ សូមផ្តល់លេខសន្តិសុខសង្គមបួនខ្ទង់ចុងក្រោយរបស់អ្នក។
**7។ ជម្រើសបក្ស។** រដ្ឋ Mississippi មិនមានការចុះឈ្មោះគណៈបក្សទេ។ ដូច្នេះ អ្នកមិនចាំបាច់ត្រូវតែចុះឈ្មោះជាមួយបក្សទេ ប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬសមាជ។
**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Mississippi អ្នកត្រូវ៖
• ជាពលរដ្ឋសហរដ្ឋអាមេរិក
• បានរស់នៅក្នុងរដ្ឋ Mississippi និងនៅក្នុងខោនធី (និងទីក្រុង បើមាន) 30 ថ្ងៃមុនការបោះឆ្នោតដែលអ្នកចង់បោះឆ្នោត
• មានអាយុ 18 ឆ្នាំត្រឹមថ្ងៃបោះឆ្នោតសកលដែលអ្នកចង់បោះឆ្នោត
• មិនត្រូវបានផ្តន្ទាទោសពីបទមនុស្សឃាត រំលោភ សូកប៉ាន់ លួច ដុតផ្ទះ រំលោភសេចក្តីទុកចិត្ត ក្លែងបន្លំ លួចប្លន់ ចាប់ជម្រិត ឧក្រិដ្ឋកម្មលាងប្រាក់កខ្វក់ ឧក្រិដ្ឋកម្មលួចហាង ទទួលផលចោរកម្មប្លន់ លួចម៉ូតូ រំលោភសេពសន្ថវៈ លួចរថយន្ត ទ្វេរពន្ធភាព ឬទទួលបានសិទ្ធិពលរដ្ឋវិញដូចតម្រូវដោយច្បាប់
• មិនត្រូវបានប្រកាសថាជាអសមត្ថជនផ្នែកស្មារតីដោយតុលាការ

*សម្គាល់៖* ច្បាប់របស់រដ្ឋបានកែប្រែដោយដីកាតុលាការសហពន្ធក្នុងឆ្នាំ1998 និងដោយច្បាប់សភាក្នុងឆ្នាំ 2000។ បច្ចុប្បន្ននេះ យើងទទួលយកទម្រង់ជាការចុះឈ្មោះសម្រាប់ការបោះឆ្នោតសម្រាប់ រាល់ រដ្ឋនិងការិយាល័យសហព័ន្ធទាំងអស់។

**អាស័យដ្ឋានប្រៃសណីយ៍**
រដ្ឋមន្រ្តី
P.O. ប្រអប់ 136
Jackson, MS 39205-0136

អាស័យដ្ឋានខោនធីនៅកម្រិតមូលដ្ឋាន៖ អ្នកក៏អាចប្រគល់ពាក្យស្នើសុំបំពេញសព្វគ្រប់នេះទៅស្ថាន/មន្ត្រីចុះបញ្ជីខោនធីនៃទីកន្លែងដែលអ្នករស់នៅ។ បញ្ជីមន្រ្តីចុះបញ្ជី/ស្ថានខោនធីមាននៅគេហទំព័ររបស់រដ្ឋ Mississippi www.sos.ms.gov។

## រដ្ឋ Missouri

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី12 ខែកញ្ញា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ** — 28 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** ទម្រង់ចុះឈ្មោះបោះឆ្នោតរបស់អ្នកត្រូវមានលេខប័ណ្ណបើកបរដែលចេញដោយរដ្ឋ។ ទម្រង់ចុះឈ្មោះអ្នកបោះឆ្នោតពេញលេញរបស់អ្នកត្រូវមានលេខសន្តិសុខសង្គមបួនខ្ទង់ចុងក្រោយ។ (ផ្នែកទី 115.155, RSMo). ប្រសិនបើអ្នកមិនមានបណ្ណបើកបរ ឬលេខសន្តិសុខសង្គមទេ ចូរសរសេរ "គ្មាន" នៅលើទម្រង់នេះ។ លេខសម្គាល់មួយនឹងត្រូវចេញឲ្យអ្នកដោយរដ្ឋ។ សារព័ត៌មានអេឡិកត្រូនិកឯកសារបោះពុម្ព ឬស្លាកផ្ញើតាមប្រៃសណីយ៍ដែលបានផ្តល់ឲ្យតាមផ្នែកនេះមិនត្រូវមានលេខទូរស័ព្ទនិងលេខសន្តិសុខសង្គមរបស់អ្នកបោះឆ្នោតឡើយ។ (ផ្នែកទី 115.157, RSMo)។
**7។ ជម្រើសបក្ស។** អ្នកមិនចាំបាច់ត្រូវតែចុះឈ្មោះជាមួយបក្សទេ ប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬសមាជ។
**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ។
**9។ ហត្ថលេខា។** ដើម្បីបោះឆ្នោតក្នុងរដ្ឋ Missouri អ្នកត្រូវ៖
• ជាពលរដ្ឋសហរដ្ឋអាមេរិក
• មានលំនៅនៅរដ្ឋ Missouri
• មានអាយុយ៉ាងតិច 17 ឆ្នាំកន្លះ (អ្នកត្រូវមានអាយុ 18 ឆ្នាំដើម្បីបោះឆ្នោត)
• មិនត្រូវជាប់ឃុំបណ្តោះអាសន្ន ឬផ្តន្ទាទោសក្រោយការប្រព្រឹត្តបទឧក្រិដ្ឋ រហូតដល់ត្រូវបានទម្លាក់ចោលនូវការឃុំឃាំងបណ្តោះអាសន្ន ឬផ្តន្ទាទោសនេះ
• មិនត្រូវបានផ្តន្ទាទោសឧក្រិដ្ឋឬមជ្ឈិមពាក់ព័ន្ធនឹងសិទ្ធិបោះឆ្នោត
• មិនត្រូវបានសម្រេចថាជាអសមត្ថជនដោយតុលាការ
• មិនត្រូវបានឃុំឃាំងដោយទោសដាក់ពន្ធនាគារ

**អាស័យដ្ឋានប្រៃសណីយ៍**
រដ្ឋមន្រ្តី
P.O. ប្រអប់ 1767
Jefferson City, MO 65102-1767

# ការណែនាំរដ្ឋ

## រដ្ឋ Montana

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ** — 30 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** អ្នកត្រូវផ្តល់លេខប័ណ្ណបើកបរនៃរដ្ឋ Montana របស់អ្នក។ ប្រសិនបើអ្នកមិនមាន លេខប័ណ្ណបើកបររបស់រដ្ឋ Montana ទេ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបរ ឬលេខសន្តិសុខសង្គមទេ ចូរសរសេរ “គ្មាន” នៅលើទម្រង់នេះ។ រដ្ឋ Montana នឹងផ្តល់លេខបញ្ជាក់អត្តសញ្ញាណមួយដល់អ្នក។

**7។ ជម្រើសបក្ស។** រដ្ឋ Montana មិនតម្រូវការចុះឈ្មោះបក្សក្នុងការចូលរួមការបោះឆ្នោតណាមួយទេ។

**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ

**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Montana អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- មានអាយុយ៉ាងតិច 18 ឆ្នាំនៅថ្ងៃ ឬមុនថ្ងៃការបោះឆ្នោតបន្ទាប់
- មានលំនៅស្ថាននៅរដ្ឋ Montanaនិងក្នុងខោនធីដែលអ្នកចង់បោះឆ្នោតយ៉ាងតិច 30 ថ្ងៃមុនការបោះឆ្នោតបន្ទាប់
- មិនត្រូវស្ថិតក្នុងទោសព្រហ្មទណ្ឌនៃបទឧក្រិដ្ឋ
- មិនត្រូវបានកំណត់ដោយតុលាការថាមានសតិមិនប្រក្រតី
- បំពេញតាមលក្ខខ័ណ្ឌទាំងនេះត្រឹមថ្ងៃបោះឆ្នោតបន្ទាប់ ក្នុងករណីដែលអ្នកមិនបានបំពេញលក្ខខ័ណ្ឌទាំងនេះនៅពេលនេះ

**អាស័យដ្ឋានប្រៃសណីយ៍**
ការិយល័យរដ្ឋមន្ត្រី
P.O. ប្រអប់ 202801
State Capitol
Helena, MT 59620-2801

## រដ្ឋ Nebraska

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ការចុះឈ្មោះ —** ថ្ងៃសុក្រទីបីមុនការបោះឆ្នោត (ឬបានបញ្ជូនត្រឹម ម៉ោង 6 ល្ងាចនៅថ្ងៃសុក្រទីពីរមុនការបោះឆ្នោត)។

**6។ លេខអត្តសញ្ញាណបណ្ណ** អ្នកត្រូវផ្តល់លេខប័ណ្ណបើកបរនៃរដ្ឋ Nebraska របស់អ្នក។ ប្រសិនបើអ្នក មិនមាន លេខប័ណ្ណបើកបរនៃរដ្ឋ Nebraska ទេ អ្នកត្រូវផ្តល់លេខបួនខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។

**7។ ជម្រើសបក្ស។** អ្នកត្រូវចុះឈ្មោះជាមួយបក្សប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬអនុសញ្ញា។

**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ

**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Nebraska អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- មានលំនៅនៅរដ្ឋ Nebraska
- មានអាយុយ៉ាងតិច 18 ឆ្នាំ ឬនឹងមានអាយុ 18 ឆ្នាំនៅថ្ងៃ ឬមុនថ្ងៃអង្គារទីមួយបន្ទាប់ពីថ្ងៃចន្ទទីមួយនៃខែវិច្ឆិកា
- មិនត្រូវបានផ្តន្ទាទោសឧក្រិដ្ឋ ឬត្រូវទទួលទោស ត្រូវទទួលបាននូវសិទ្ធិពលរដ្ឋឡើងវិញ
- មិនត្រូវបានរកឃើញថាជាអសមត្ថជនផ្នែកស្មារតីជាផ្លូវការ

**អាស័យដ្ឋានប្រៃសណីយ៍**
រដ្ឋមន្ត្រីរដ្ឋ Nebraska
Suite 2300, State Capitol Bldg.
Lincoln, NE 68509-4608

## រដ្ឋ Nevada

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី07 ខែឧសភា ឆ្នាំ2010**

**កាលកំណត់ការចុះឈ្មោះ** — កាលកំណត់សម្រាប់ការចុះឈ្មោះតាមម៉ែលគឺនៅថ្ងៃសៅរ៍ទីប្រាំមុនការបោះឆ្នោតសកល ឬបោះឆ្នោតបឋម។ ការចុះឈ្មោះដោយផ្ទាល់នៅបន្ទប់រហូតដល់ម៉ោង 9:00 យប់ ថ្ងៃអង្គារទីបីមុនការបោះឆ្នោតសកលឬការបោះឆ្នោតបឋម។ អ្នកអាចចុះឈ្មោះដោយផ្ទាល់ដោយបង្ហាញវត្តមាននៅការិយាល័យនៃស្នងការ/មន្ត្រីចុះឈ្មោះសម្រាប់អ្នកបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** អ្នក ត្រូវ ផ្តល់លេខប័ណ្ណបើកបរនៃរដ្ឋ Nevada ឬលេខអត្តសញ្ញាណប័ណ្ណនៃរដ្ឋ Nevada បើអ្នកត្រូវបានចេញឲ្យណាមួយ។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបររបស់រដ្ឋ Nevada ឬអត្តសញ្ញាណប័ណ្ណទេ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ប្រសិនបើអ្នកមិនមានលេខសន្តិសុខសង្គមទេ សូមទាក់ទងមកមន្ត្រី/ស្នងខោនធីសម្រាប់អ្នកបោះឆ្នោតដើម្បីឲ្យផ្តល់ការកំណត់អត្តសញ្ញាណមួយ។

**7។ ជម្រើសបក្ស។** អ្នកត្រូវចុះឈ្មោះជាមួយបក្សប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬអនុសញ្ញា។ ប្រសិនបើអ្នកចុះឈ្មោះជាមួយបក្សនយោបាយតូចៗ ឬគ្មានបក្សនយោបាយ អ្នកនឹងទទួលបានសន្លឹកឆ្នោតគ្មានបក្សសម្រាប់ការបោះឆ្នោតបឋម។

**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ

**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Nevada អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- មានអាយុ 18 ឆ្នាំត្រឹមថ្ងៃបោះឆ្នោតបន្ទាប់
- ស្នាក់នៅជាបន្តបន្ទាប់ក្នុងរដ្ឋ Nevada នៅក្នុងខោនធី យ៉ាងតិច 30 ថ្ងៃ និងក្នុងកន្លែងបោះឆ្នោតយ៉ាងតិច 10 ថ្ងៃមុនការបោះឆ្នោតបន្ទាប់
- ត្រូវបានផ្តល់សិទ្ធិជាពលរដ្ឋឡើងវិញ ប្រសិនបើអ្នកត្រូវបានផ្តន្ទាទោសឧក្រិដ្ឋ
- មិនត្រូវបានកំណត់ថាជាអសមត្ថជនផ្នែកស្មារតីដោយតុលាការ
- មិនទាមទារថាកន្លែងផ្សេងជាលំនៅស្ថានស្របច្បាប់របស់ខ្លួន

**អាស័យដ្ឋានប្រៃសណីយ៍**
រដ្ឋមន្ត្រី
ផ្នែកការបោះឆ្នោត
101 North Carson Street
Suite 3
Carson City, NV 89701-4786

ពាក្យស្នើសុំអាចត្រូវបានបង្ហិលទៅការិយាល័យរដ្ឋមន្ត្រីនៅអាស័យដ្ឋានខាងលើ ប៉ុន្តែចៀសវាងការបន្សាពេល សូមណែនាំឲ្យដាក់ពាក្យស្នើសុំចុះបញ្ជីពេញលេញរបស់

អ្នកទៅផ្ទាល់មន្ត្រីការបោះឆ្នោតខោនធីមូលដ្ឋាន។

**អាស័យដ្ឋានខោនធីនៅកម្រិតមូលដ្ឋាន៖** ដើម្បីឲ្យទាន់កាលកំណត់ចុះឈ្មោះ ជាពិសេសអំឡុងពេលពីរសប្តាហ៍មុនការបិទកាលកំណត់ទទួលតាមម៉ែល ត្រូវបញ្ជូនពាក្យស្នើសុំពេញលេញរបស់អ្នកទៅមន្ត្រីចុះបញ្ជី/ស្នានខោនធីសម្រាប់អ្នកចុះបញ្ជីនីមួយៗ។ បញ្ជីរាយមន្ត្រីចុះបញ្ជី/ស្នានខោនធីសម្រាប់អ្នកបោះឆ្នោត និងកាលកំណត់ចុះបញ្ជីមាននៅលើគេហទំព័ររបស់រដ្ឋ Nevada www.nvsos.gov។

## រដ្ឋ New Hampshire

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ** —ស្មានទីក្រុងនៃរដ្ឋ New Hampshire នឹងទទួលយកពាក្យស្នើសុំនេះតែក្នុងករណីដែលការស្នើសុំសម្រាប់អវត្តមានអ្នកបោះឆ្នោតផ្ញើតាមម៉ែលដែលត្រូវទទួលដោយស្មានទីក្រុងត្រឹម 10 ថ្ងៃមុនការបោះឆ្នោត។

ស្មាននៃទីក្រុងនិងទីប្រជុំជន New Hampshire នឹងទទួលយកទម្រង់បែបបទនេះតែក្នុងករណីមានសំណើចំពោះអវត្តមានអ្នកបោះឆ្នោតដោយផ្ញើចូលនូវទម្រង់ចុះឈ្មោះ។ អ្នកត្រូវបំពេញក្នុងប្រអប់លេខ 1 និង 2 ឬ 3។

ពាក្យស្នើសុំគួត្រូវម៉ែលទៅកាន់ស្មានទីក្រុងនៅលេខហ្ស៊ីបកូដរបស់អ្នក។ អាស័យដ្ឋានទាំងនេះត្រូវបានរាយនៅលើគេហទំព័ររដ្ឋមន្ត្រី www.state.nh.us/sos/clerks.htm

វាគួត្រូវបានផ្ញើម៉ែលទៅស្មានទីក្រុងរបស់អ្នកក្នុងរយៈពេលយូរដើម្បីឲ្យពួកគេអាចផ្ញើទម្រង់របស់គេឲ្យអ្នក។ បន្ទាប់មកអ្នកត្រូវបំពេញរួចបញ្ជូនទៅគេវិញត្រឹម 10 ថ្ងៃមុនការបោះឆ្នោត។election.

## រដ្ឋ New Jersey

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី28 ខែមីនា ឆ្នាំ2008**

**កាលកំណត់ចុះឈ្មោះ** — 21 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** លេខសន្តិសុខសង្គមបួនខ្ទង់ចុងក្រោយ ឬលេខប័ណ្ណបើកបរនៃរដ្ឋ New Jersey របស់អ្នកត្រូវផ្តល់ជូនសម្រាប់ការចុះឈ្មោះអ្នកបោះឆ្នោត។ ប្រសិនបើអ្នកមិនមានលេខបញ្ជាក់អត្តសញ្ញាណទាំងនេះ សូមសរសេរ "គ្មាន" នៅលើទម្រង់នេះ។ រដ្ឋនឹងផ្តល់លេខមួយដែលនឹងបញ្ជាក់អត្តសញ្ញាណរបស់អ្នកសម្រាប់គោលបំណងនៃការចុះឈ្មោះអ្នកបោះឆ្នោត។

**7។ ជម្រើសបក្ស។**
ទម្រង់ចុះឈ្មោះអ្នកបោះឆ្នោតរដ្ឋ New Jersey មិនផ្តល់ការពិនិត្យសម្ព័ន្ធភាពគណបក្សនយោបាយទេ។ អ្នកចុះឈ្មោះបោះឆ្នោតថ្មីឬអ្នកបោះឆ្នោតដែលមិនធ្លាប់បោះឆ្នោតបឋមគណបក្សនយោបាយ អាចប្រកាសអំពីគណបក្សសម្ព័ន្ធរបស់ខ្លួនទីមណ្ឌលបោះឆ្នោតនៅថ្ងៃបោះឆ្នោតបឋម។ ក្នុងរដ្ឋ New Jersey ការបោះឆ្នោតបឋមគឺមានសម្រាប់តែគណបក្សប្រជាធិបតេយ្យ និងគណបក្សសាធារណរដ្ឋប៉ុណ្ណោះ។ អ្នកបោះឆ្នោតក៏អាចដាក់ទម្រង់ប្រកាសគណៈបក្សនយោបាយដើម្បីក្លាយជាសមាជិកនៃគណបក្សនយោបាយនោះដែរ។ ប្រសិនបើអ្នកបោះឆ្នោតដែលបានប្រកាសចង់ប្តូរសម្ព័ន្ធបក្សនយោបាយ គាត់ត្រូវដាក់ទម្រង់ប្រកាសមួយក្នុងរយៈពេល 50 ថ្ងៃមុនការបោះឆ្នោតបឋមដើម្បីបោះឆ្នោត។

**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ

**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ New Jersey អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- មានអាយុយ៉ាងតិច 18 ឆ្នាំនៅពេលបោះឆ្នោតបន្ទាប់
- មានលំនៅស្ថានក្នុងរដ្ឋនេះនិងក្នុងខោនធីនៃអាស័យដ្ឋានរបស់អ្នក 30 ថ្ងៃមុនការបោះឆ្នោតបន្ទាប់
- មិនត្រូវផ្តន្ទាទោស ឬជាប់ឃុំឬឃុំបណ្តោះអាសន្នដែលជាលទ្ធផលនៃការប្រព្រឹត្តឧក្រិដ្ឋកម្មក្រោមច្បាប់នៃរដ្ឋនេះឬរដ្ឋផ្សេងនៃសហរដ្ឋអាមេរិក

**អាស័យដ្ឋានប្រៃសណីយ៍**

ក្រសួងច្បាប់និងសន្តិសុខសាធារណៈនៃរដ្ឋ New Jersey
ផ្នែករៀបចំការបោះឆ្នោត
PO Box 304
Trenton, NJ 08625-0304

## រដ្ឋ New Mexico

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ** — 28 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** លេខសន្តិសុខសង្គមពេញរបស់អ្នកគឺជាតម្រូវការចាំបាច់។ ប័ណ្ណចុះឈ្មោះដែលមានលេខសន្តិសុខសង្គមរបស់អ្នកនេះនឹងក្លាយផ្នែកមួយនៃកំណត់ត្រាចុះឈ្មោះអ្នកបោះឆ្នោតជាអចិន្ត្រៃយ៍នៃទីតាំងរបស់អ្នក ដែលបើកចំហរសម្រាប់ការត្រួតពិនិត្យជាសាធារណៈនៅក្នុងការិយាល័យនៃស្មានខោនធី។ ទោះបីជាយ៉ាងនេះក្តីលេខសន្តិសុខសង្គមរបស់អ្នកនិងថ្ងៃខែឆ្នាំកំណើតត្រូវរក្សាការសម្ងាត់និងមិនត្រូវប្រកាសជាសាធារណៈឡើយ។ ការរាយបញ្ជីដោយកុំព្យូទ័រនៃការម្រិតព័ត៌មានការចុះបញ្ជីអ្នកបោះឆ្នោត (ដោយគ្មានលេខសន្តិសុខសង្គមឬថ្ងៃខែឆ្នាំកំណើត)អាចឲ្យសាធារណជនមើលបាន និងត្រូវបានបញ្ចប់តាមរយៈសំណើរបស់អ្នកកាន់ការិយាល័យបោះឆ្នោត បេក្ខជនបក្សនយោបាយ តុលាការ ឬអង្គការមិនរកប្រាក់ចំណេញលើកកម្ពស់អ្នកបោះឆ្នោតចូលរួមនិងចុះឈ្មោះសម្រាប់គោលនយោបាយប៉ុណ្ណោះ (§1-5-19B, NMSA 1978)។

**7។ ជម្រើសបក្ស។** អ្នកត្រូវចុះឈ្មោះជាមួយបក្សប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះជាការប្រជុំបក្ស ឬអនុសញ្ញា។

**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ។

**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះក្នុងរដ្ឋ New Mexico អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- ស្នាក់នៅក្នុងរដ្ឋ New Mexico
- មានអាយុ 18 ឆ្នាំនៅពេលបោះឆ្នោតបន្ទាប់
- មិនត្រូវបានបដិសេធសិទ្ធិបោះឆ្នោតដោយតុលាការដោយដោយហេតុអសមត្ថភាពផ្នែកស្មារតី និងប្រសិនបើត្រូវបានផ្តន្ទាទោសឧក្រិដ្ឋ ខ្ញុំបានអនុវត្តរាល់លក្ខខណ្ឌនៃការឃុំខ្លួន ឬឃុំឃាំង អនុវត្តទោសចប់សព្វគ្រប់ឬទទួលបានការលើកលែងទោសពីរដ្ឋបាល។

**អាស័យដ្ឋានប្រៃសណីយ៍**
ការិយាល័យបោះឆ្នោត
325 Don Gaspar, Suite 300
Santa Fe, NM 87503

## រដ្ឋ New York

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី19 ខែឧសភា ឆ្នាំ2014**

**កាលកំណត់ចុះឈ្មោះ —** 25 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** ច្បាប់សហព័ន្ធតម្រូវថាអ្នកត្រូវផ្តល់លេខប័ណ្ណបើកបររបស់អ្នកដើម្បីចុះឈ្មោះបោះឆ្នោត។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបរ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ប្រសិនបើអ្នកមិនមានលេខណាមួយទេ សូមសរសេរ "គ្មាន" នៅលើទម្រង់នេះ។ លេខសម្គាល់មួយនឹងត្រូវចេញឲ្យអ្នកដោយរដ្ឋ។
**7។ ជម្រើសបក្ស។** អ្នកត្រូវចុះឈ្មោះជាមួយបក្សប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ។
**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ។
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះក្នុងរដ្ឋ New York អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- មានលំនៅស្ថាននៅក្នុងខោនធី ឬទីក្រុង New York យ៉ាងតិច 30 ថ្ងៃមុនការបោះឆ្នោត
- មានអាយុ 18 ឆ្នាំត្រឹមថ្ងៃទី 31 ខែធ្នូ នៃឆ្នាំដែលដាក់ទម្រង់នេះ (*សម្គាល់៖* មានអាយុ 18 ឆ្នាំត្រឹមថ្ងៃបោះឆ្នោតសកល បោះឆ្នោតបឋម ឬបោះឆ្នោតផ្សេងៗដែលអ្នកចង់បោះឆ្នោត)
- មិនជាប់ពន្ធនាគារឬឃុំខ្លួនពីបទឧក្រិដ្ឋ
- មិនត្រូវបានសម្រេចដោយដីកាតុលាការមានសមត្ថកិច្ចជាអសមត្ថជន
- មិនទាមទារសិទ្ធិបោះឆ្នោតនៅកន្លែងផ្សេងទៀត

**អាស័យដ្ឋានប្រៃសណីយ៍**
ក្រុមប្រឹក្សារដ្ឋ NYSនៃការបោះឆ្នោត
40 North Pearl Street, Suite 5
Albany, NY 12207-2729

## រដ្ឋ North Carolina

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ** — តាមប្រៃសណីយ៍ 25 ថ្ងៃមុនការបោះឆ្នោត ឬទទួលនៅកាលវិយាល័យបោះឆ្នោតឬភ្នាក់ងារចុះឈ្មោះអ្នកបោះឆ្នោតដែលបានចាត់តាំងត្រឹមម៉ោង 5:00 ល្ងាច។ 25 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ**
ផ្តល់លេខប័ណ្ណបើកបរនៃរដ្ឋ North Carolina របស់អ្នក ឬលេខសម្គាល់យានបន្តនៃក្រសួង North Carolina Department។ ប្រសិនបើអ្នកមិនមានបណ្ណបើកបរទេ សូមផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។
**7។ ជម្រើសបក្ស។** អ្នកត្រូវចុះឈ្មោះជាមួយបក្សនយោបាយដើម្បីបោះឆ្នោតបឋមនៃបក្សនោះ លើកលែងតែបក្សនោះអនុញ្ញាតឲ្យអ្នកបោះឆ្នោតមិនមានសម្ព័ន្ធបោះឆ្នោតបឋមរបស់ខ្លួន។ ប្រសិនបើអ្នកបញ្ជាក់ថាគណបក្សណាមួយគ្មានលក្ខណសម្បត្តិ ឬបញ្ជាក់ថាគ្មានបក្ស អ្នកនឹងត្រូវចុះបញ្ជីថា "គ្មានសម្ព័ន្ធបក្ស"។
**8។ សាសន៍ ឬក្រុមជនជាតិ** អ្នកត្រូវបានស្នើក្នុងការបំពេញក្នុងប្រអប់នេះ។ ទោះជាយ៉ាងនេះក្តី ពាក្យស្នើសុំរបស់អ្នកនឹងមិនត្រូវបានបដិសេធឡើយ បើអ្នកមិនបានបំពេញបានជោគជ័យតាមនោះ។ សូមមើលបញ្ជីជម្រើសនៅក្នុងការណែនាំសម្រាប់ពាក្យស្នើសុំនៅប្រអប់ទី 8 (នៅទំព័រ 2)។
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ North Carolina អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- មានលំនៅស្ថាននៅរដ្ឋ North Carolina និងក្នុងខោនធីដែលអ្នករស់នៅយ៉ាងតិច 30 ថ្ងៃមុនការបោះឆ្នោត
- មានអាយុយ៉ាងតិច 18 ឆ្នាំនៅថ្ងៃបោះឆ្នោតសកលបន្ទាប់
- បានទទួលសម្បទាសិទ្ធិជាពលរដ្ឋវិញ បើអ្នកត្រូវបានផ្តន្ទាទោសឧក្រិដ្ឋ
- មិនត្រូវបានចុះឈ្មោះ ឬបោះឆ្នោតនៅខោនធីឬរដ្ឋផ្សេង

**អាស័យដ្ឋានប្រៃសណីយ៍**
ក្រុមប្រឹក្សារដ្ឋនៃការបោះឆ្នោត
P.O. ប្រអប់ 27255
Raleigh, NC 27611-7255

## រដ្ឋ North Dakota

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

នៅរដ្ឋ North Dakot មិនមានការចុះឈ្មោះអ្នកបោះឆ្នោតទេ។

## រដ្ឋ Ohio

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ —** 30 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** លេខសន្តិសុខសង្គមពេញរបស់អ្នកគឺជាតម្រូវការចាំបាច់។ ការផ្តល់លេខនេះគឺឈរលើមូលដ្ឋានស្ម័គ្រចិត្ត។ ព័ត៌មាននេះអនុញ្ញាតឲ្យក្រុមប្រឹក្សាបោះឆ្នោតពិនិត្យការចុះឈ្មោះរបស់អ្នកបើចាំបាច់ (Q.R.C 3503.14). [ច្បាប់សហព័ន្ធតម្រូវថាអ្នកត្រូវផ្តល់លេខប័ណ្ណបើកបររបស់អ្នកដើម្បីចុះឈ្មោះបោះឆ្នោត។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបរ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ប្រសិនបើអ្នកមិនមានលេខណាមួយទេ អ្នកត្រូវសរសេរ "គ្មាន" នៅលើទម្រង់ ហើយរដ្ឋនឹងផ្តល់លេខមួយឲ្យអ្នក។]
**7។ ជម្រើសបក្ស។** អ្នកមិនចាំបាច់ចុះឈ្មោះជាមួយបក្សប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ។ សម្ព័ន្ធបក្សត្រូវបានបង្កើតដោយការបោះឆ្នោតនៅការបោះឆ្នោតបឋម។
**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ។
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Ohio អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- មានលំនៅនៅរដ្ឋ Ohio
- មានអាយុ 18 ឆ្នាំនៅមុន ឬនៅថ្ងៃបោះឆ្នោត ប្រសិនបើអ្នកនឹងមានអាយុ 18 ឆ្នាំនៅថ្ងៃ ឬមុនថ្ងៃបោះឆ្នោតសកល អ្នកអាចបោះឆ្នោតបឋមសម្រាប់តែបេក្ខភាពនោះប៉ុណ្ណោះ។
- មិនត្រូវជាប់ពន្ធនាគារពីបទឧក្រិដ្ឋនិងកំពុងជាប់ឃុំ

• មិនត្រូវប្រកាសថាអសមត្ថភាពដោយតុលាការសម្រាប់គោលបំណងនៃការបោះឆ្នោត

**អាស័យដ្ឋានប្រៃសណីយ៍**
រដ្ឋមន្ត្រីរដ្ឋ Ohio
ផ្នែកការបោះឆ្នោត
ផ្លូវ 180 E. Broad Street — ជាន់ទី 15
Columbus, OH 43215

## រដ្ឋ Oklahoma

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី29 ខែតុលា ឆ្នាំ2003**

**កាលកំណត់ចុះឈ្មោះ** — 25 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** លេខសន្តិសុខសង្គមបួនខ្ទង់ចុងក្រោយរបស់អ្នកត្រូវបានតម្រូវ។ (ច្បាប់រដ្ឋ Oklahoma 26 ផ្នែកទី 4-112) បន្ថែមពីនេះ លេខបណ្ណបើកបរនៃរដ្ឋ Oklahoma របស់អ្នកតម្រូវជាចាំបាច់។
**7។ ជម្រើសបក្ស។** អ្នកត្រូវចុះឈ្មោះជាមួយបក្សប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬអនុសញ្ញា។
**8។ សាសន៍ ឬក្រុមជនជាតិ** សូមទុកឲ្យនៅទំនេរ
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Oklahoma អ្នកត្រូវ៖
• ជាពលរដ្ឋសហរដ្ឋអាមេរិកនិងស្នាក់នៅក្នុងរដ្ឋ Oklahoma
• មានអាយុ 18 ឆ្នាំនៅថ្ងៃ ឬមុនថ្ងៃការបោះឆ្នោតបន្ទាប់
• មិនត្រូវបានផ្តន្ទាទោសឧក្រិដ្ឋសម្រាប់រយៈពេលស្មើនឹងទោសដើមបានផុត ឬសម្រាប់ដែលអ្នកមិនត្រូវបានលើកលែងទោស
• មិនស្ថិតនៅក្រោមសាលក្រមជាបុគ្គលអសមត្ថភាព ឬជាបុគ្គលអសមត្ថភាពដោយផ្នែកត្រូវបានហាមឃាត់ពីការចុះឈ្មោះបោះឆ្នោត

**អាស័យដ្ឋានប្រៃសណីយ៍**
ក្រុមប្រឹក្សាបោះឆ្នោតរដ្ឋ Oklahoma
ប្រអប់ 528800
ទីក្រុង Oklahoma, OK 73152-8800

## រដ្ឋ Oregon

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ** — 21 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** ច្បាប់សហព័ន្ធតម្រូវថាអ្នកត្រូវផ្តល់លេខប័ណ្ណបើកបររបស់អ្នកដើម្បីចុះឈ្មោះបោះឆ្នោត។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបរ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ប្រសិនបើអ្នកមិនមានលេខណាមួយទេ អ្នកចាំបាច់ត្រូវសរសេរ "គ្មាន" នៅលើទម្រង់នេះ។លេខសម្គាល់មួយនឹងត្រូវចេញជាជំនួសឲ្យអ្នកដោយរដ្ឋ។
**7។ ជម្រើសបក្ស។** អ្នកត្រូវចុះឈ្មោះជាមួយបក្សប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ។
**8។ សាសន៍ ឬក្រុមជនជាតិ** សូមទុកឲ្យនៅទំនេរ
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Oregon អ្នកត្រូវ៖
• ជាពលរដ្ឋសហរដ្ឋអាមេរិក
• មានលំនៅនៅរដ្ឋ Oregon
• មានអាយុយ៉ាងតិច 18 ឆ្នាំនៅថ្ងៃបោះឆ្នោត

**អាស័យដ្ឋានប្រៃសណីយ៍**
រដ្ឋមន្ត្រី
ផ្នែកការបោះឆ្នោត
141 State Capitol
Salem, OR 97310-0722

## រដ្ឋ Pennsylvania

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ** — 30 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** អ្នកត្រូវដាក់លេខប័ណ្ណបើកបររបស់អ្នក បើអ្នកមាន។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបរ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ប្រសិនបើអ្នកមិនមានលេខសន្តិសុខសង្គមទេ ចូរសរសេរ "គ្មាន" នៅក្នុងប្រអប់នេះ។
**7។ ជម្រើសបក្ស។** អ្នកត្រូវចុះឈ្មោះជាមួយបក្សប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ។
**8។ សាសន៍ ឬក្រុមជនជាតិ** អ្នកត្រូវបានស្នើសុំក្នុងការបំពេញក្នុងប្រអប់នេះ។ សូមមើលបញ្ជីជម្រើសនៅក្នុងការណែនាំសម្រាប់ពាក្យស្នើសុំនៅប្រអប់ទី 8 (នៅទំព័រ 2)។
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Pennsylvania អ្នកត្រូវ៖
• ជាពលរដ្ឋសហរដ្ឋអាមេរិកយ៉ាងហោចណាស់មួយខែមុនការបោះឆ្នោតបន្ទាប់
• ស្នាក់នៅក្នុងរដ្ឋ Pennsylvania និងស្រុកការិយាល័យបោះឆ្នោតរបស់អ្នកយ៉ាងហោចណាស់ 30 ថ្ងៃមុនការបោះឆ្នោត
• មានអាយុយ៉ាងតិច 18 ឆ្នាំនៅថ្ងៃបោះឆ្នោតសកលបន្ទាប់

**អាស័យដ្ឋានប្រៃសណីយ៍**
ការិយាល័យលេខាធិការរដ្ឋនៃ
the Commonwealth
210 North Office Bldg.
Harrisburg, PA 17120-0029

## រដ្ឋ Rhode Island

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី28 ខែមីនា ឆ្នាំ2008**

**កាលកំណត់ចុះឈ្មោះ** — 30 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** អ្នកដាក់ពាក្យស្នើសុំត្រូវតម្រូវឲ្យផ្តល់លេខប័ណ្ណបើកបរនៃរដ្ឋ Rhode Island របស់អ្នក ប្រសិនបើអ្នកត្រូវបានចេញឲ្យនូវប័ណ្ណបើកបរដែលមានសុពលភាពនិងបច្ចុប្បន្ន។ ក្នុងករណីដែលអ្នកដាក់ពាក្យស្នើសុំដែលមិនបានចេញប័ណ្ណបើកបរមានសុពលភាពនិងបច្ចុប្បន្ន គាត់ត្រូវផ្តល់លេខសន្តិសុខសង្គមបួនខ្ទង់ចុងក្រោយរបស់អ្នក។ អ្នកដាក់ពាក្យស្នើសុំ ដែលមិនមានប័ណ្ណនឹងត្រូវចេញលេខបញ្ជាក់ពិសេសមួយដោយរដ្ឋ Rhode Island។
**7។ ជម្រើសបក្ស។** នៅក្នុងរដ្ឋ Rhode Island បុគ្គលត្រូវចុះឈ្មោះជាមួយបក្សប្រសិនបើគាត់ចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ។ បុគ្គលដែលខកខានចុះឈ្មោះជាមួយបក្សនយោបាយនៅពេលចុះឈ្មោះ អាចចុះឈ្មោះជាមួយបក្សនៅថ្ងៃបោះឆ្នោតបឋមនិងចូលរួមជាផ្

នៃកនៅក្នុងការបោះឆ្នោតរបស់បក្សនោះ បើគាត់ជ្រើសដូច្នេះ។ ប្រសិនបើអ្នកមិនចុះឈ្មោះជាមួយគណៈបក្សទេ គាត់នៅតែអាចបោះឆ្នោតទូទៅនិងការបោះឆ្នោតបឋមដោយគ្មានបក្សដែរ។

**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ។

**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Rhode Island អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- មានលំនៅស្ថាននៅរដ្ឋ Rhode Island រយៈ 30 ថ្ងៃមុនការបោះឆ្នោតបន្ទាប់
- មានអាយុយ៉ាងតិច 18 ឆ្នាំត្រឹមថ្ងៃបោះឆ្នោត
- មិនត្រូវបានជាប់ឃុំក្នុងមណ្ឌលកែប្រែដោយទទួលពីបទឧក្រិដ្ឋ
- មិនត្រូវបានរកឃើញថាជាអសមត្ថជនផ្នែកស្មារតីតាមផ្លូវច្បាប់

**អាស័យដ្ឋានប្រៃសណីយ៍**
ក្រុមប្រឹក្សារដ្ឋ Rhode Island
នៃការបោះឆ្នោត
50 Branch Ave.
Providence, RI 02904-2790

## រដ្ឋ South Carolina

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ** — 30 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** លេខសន្តិសុខសង្គមពេញរបស់អ្នកគឺជាតម្រូវការចាំបាច់។ វាត្រូវបានតម្រូវដោយច្បាប់ក្រមនៃរដ្ឋ South Carolina ហើយត្រូវបានប្រើសម្រាប់គោលបំណងផ្ទៃក្នុងប៉ុណ្ណោះ។ លេខសន្តិសុខសង្គមមិនឃើញមាននៅលើរបាយការណ៍ដែលរៀបចំដោយគណៈកម្មការបោះឆ្នោតជាតិណាមួយឬ ត្រូវបានបញ្ចេញដោយគ្មានការយល់ព្រមពីបុគ្គលនោះឡើយ។ (រដ្ឋ South Carolina ជំពូក 7-5-170)

**7។ ជម្រើសបក្ស។** អ្នកមិនចាំបាច់ត្រូវតែចុះឈ្មោះជាមួយបក្សទេ ប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬសមាជ។

**8។ សាសន៍ ឬក្រុមជនជាតិ** អ្នកត្រូវបានស្នើសក្នុងការបំពេញក្នុងប្រអប់នេះ។ ពាក្យស្នើសុំរបស់អ្នកអាចនឹងត្រូវបានបដិសេធ បើអ្នកមិនបានបំពេញតាមនោះ។ សូមមើលបញ្ជីជម្រើសនៅក្នុងការណែនាំសម្រាប់ពាក្យស្នើសុំនៅប្រអប់ទី 8 (នៅទំព័រ 2)។

**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ South Carolina អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- មានអាយុយ៉ាងតិច 18 ឆ្នាំនៅថ្ងៃ ឬមុនថ្ងៃការបោះឆ្នោតបន្ទាប់
- មានលំនៅស្ថាននៅរដ្ឋ South Carolina ដែលជាខោនធីនិងកន្លែងរបស់អ្នក
- មិនត្រូវបានឃុំឃាំងក្នុងពន្ធនាគារសាធារណៈណាមួយដែលជាលទ្ធផលនៃការផ្តន្ទាទោសព្រហ្មទណ្ឌ
- មិនធ្លាប់ត្រូវផ្តន្ទាទោសឧក្រិដ្ឋ ឬបទល្មើសប្រឆាំងច្បាប់បោះឆ្នោត ឬបើធ្លាប់ផ្តន្ទាទោស បានអនុវត្តទោសពេញលេញ រួមទាំងការឃុំខ្លួន ឬការបង្ខាំង ឬបានទទួលការលើកលែងទោស
- មិនស្ថិតក្រោមដីកាតុលាការប្រកាសអសមត្ថភាពផ្នែកស្មារតី
- ទាមទារថាអាស័យដ្ឋាននៅលើពាក្យស្នើសុំគឺជាអាស័យដ្ឋានស្របច្បាប់ ឬលំនៅស្ថានរបស់អ្នក ឬទាមទារថាមិនមានលំនៅស្ថានស្របផ្សេងទៀត

**អាស័យដ្ឋានប្រៃសណីយ៍**
គណៈកម្មការបោះឆ្នោតរដ្ឋ
P.O. ប្រអប់ 5987
Columbia, SC 29250-5987

## រដ្ឋ South Dakota

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ** — បានទទួល 15 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** លេខប័ណ្ណបើកបររបស់អ្នកត្រូវបានតម្រូវ។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបរមានសុពលភាព អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។

**7។ ជម្រើសបក្ស។** អ្នកត្រូវចុះឈ្មោះជាមួយបក្សប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬអនុសញ្ញា។

**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ

**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ South Dakota អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- មានលំនៅស្ថាននៅក្នុងរដ្ឋ South Dakota
- មានអាយុ 18 ឆ្នាំត្រឹមថ្ងៃការបោះឆ្នោតបន្ទាប់
- មិនកំពុងអនុវត្តទោសសម្រាប់ការផ្តន្ទាទោសឧក្រិដ្ឋ ដែលរួមទាំងការដាក់ពន្ធនាគារ ការអនុវត្ត ឬញ្ញើរ តាមប្រព័ន្ធពន្ធនាគារមនុស្សពេញវ័យ
- មិនត្រូវបានប្រកាសថាជាអសមត្ថជនផ្នែកស្មារតីដោយតុលាការ

**អាស័យដ្ឋានប្រៃសណីយ៍**
រដ្ឋមន្ត្រី ការបោះឆ្នោត
500 E. Capitol
Pierre, SD 57501-5070

## រដ្ឋ Tennessee

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី19 ខែឧសភា ឆ្នាំ2014**

**កាលកំណត់ចុះឈ្មោះ** — 30 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** លេខសន្តិសុខសង្គមពេញរបស់អ្នកគឺជាតម្រូវការចាំបាច់។ ក្នុងករណីខ្លះ លេខសន្តិសុខសង្គមត្រូវបានតម្រូវសម្រាប់គោលបំណងនៃការកំណត់អត្តសញ្ញាណនិងដើម្បីកុំឲ្យមានការចុះឈ្មោះត្រួតគ្នា (TCA 2.2.116).

**7។ ជម្រើសបក្ស។** អ្នកមិនចាំបាច់ត្រូវតែចុះឈ្មោះជាមួយបក្សទេ ប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬសមាជ។

**8។ សាសន៍ ឬក្រុមជនជាតិ** ជម្រើស

**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Tennessee អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- មានលំនៅនៅរដ្ឋ Tennessee
- មានអាយុយ៉ាងតិច 18 ឆ្នាំនៅថ្ងៃ ឬមុនថ្ងៃការបោះឆ្នោតបន្ទាប់
- មិនត្រូវបានផ្តន្ទាទោសឧក្រិដ្ឋ ឬបើធ្លាប់ផ្តន្ទាទោស ត្រូវបានផ្តល់សិទ្ធិពលរដ្ឋពេញលេញវិញ (ឬបានទទួលការលើកលែងទោស)
- មិនត្រូវបានសម្រេចដោយតុលាការថាជាអសមត្ថជនដោយតុលាការមានសមត្ថកិច្ច (ឬត្រូវបានផ្តល់សម្បទាមានសមត្ថភាពស្របច្បាប់)

# ការណែនាំរដ្ឋ

**អាស័យដ្ឋានប្រៃសណីយ៍**
អ្នកសម្របសម្រួលការបោះឆ្នោត
Tennessee Tower, Seventh Floor
312 Rosa L. Parks Ave.
Nashville, TN 37243-1102

## រដ្ឋ Texas

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ** — 30 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** អ្នកត្រូវផ្តល់លេខប័ណ្ណបើកបររបស់អ្នកដើម្បីចុះឈ្មោះបោះឆ្នោត។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបរ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ប្រសិនបើអ្នកមិនមានលេខណាមួយទេ សូមសរសេរ “គ្មាន” នៅលើទម្រង់នេះ។ លេខសម្គាល់មួយនឹងត្រូវចេញជាជំនួសឲ្យអ្នកដោយរដ្ឋ។

**7។ ជម្រើសបក្ស។** អ្នកមិនចាំបាច់ត្រូវតែចុះឈ្មោះជាមួយបក្សទេ ប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬសមាជ។

**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ

**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Texas អ្នកត្រូវ៖
• ជាពលរដ្ឋសហរដ្ឋអាមេរិក
• មានលំនៅស្ថានក្នុងខោនធីដែលពាក្យស្នើសុំចុះឈ្មោះរបស់អ្នកបានធ្វើឡើង
• មានអាយុយ៉ាងតិច 17 ឆ្នាំ និង 10 ខែ (អ្នកត្រូវមានអាយុ 18 ឆ្នាំដើម្បីអាចបោះឆ្នោត)
• មិនត្រូវបានផ្តន្ទាទោសឧក្រិដ្ឋស្ថាពរ ឬបើត្រូវផ្តន្ទាទោស អ្នកត្រូវបានទម្លាក់ចោលទោសទណ្ឌទាំងអស់រួមទាំងការឃុំឃាំង ការឲ្យនៅក្រៅឃុំ ការត្រួតពិនិត្យ រយៈពេលសាកល្បងឬត្រូវបានលើកលែងទោស។
• មិនត្រូវបានប្រកាសថាជាអសមត្ថជនផ្នែកស្មារតីដោយសាលក្រមស្ថាពររបស់តុលាការ

**អាស័យដ្ឋានប្រៃសណីយ៍**
ការិយាល័យលេខាធិការរដ្ឋ
ផ្នែកការបោះឆ្នោត
P.O. ប្រអប់ 12060
Austin, TX 78711-2060

## រដ្ឋ Utah

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី28 ខែមីនា ឆ្នាំ2008**

**កាលកំណត់ចុះឈ្មោះ** — 30 ថ្ងៃមុនការបោះឆ្នោតសម្រាប់ពាក្យស្នើសុំតាមម៉ែល 15ថ្ងៃមុនការបោះឆ្នោតសម្រាប់ការចុះឈ្មោះដល់ការិយាល័យស្មៀនខោនធី។

**6។ លេខអត្តសញ្ញាណបណ្ណ** ទម្រង់ចុះឈ្មោះបោះឆ្នោតរបស់អ្នកត្រូវមានលេខប័ណ្ណបើកបរដែលចេញដោយរដ្ឋ ឬលេខអត្តសញ្ញាណមិនប្រតិបត្តិការរបស់អ្នក។ ប្រសិនបើអ្នកមិនមានបណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណទេ
អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបរ ឬប័ណ្ណបញ្ជាក់មិនប្រតិបត្តិការ ឬលេខសន្តិសុខសង្គមទេ ចូរសរសេរ “គ្មាន” នៅលើទម្រង់នេះ។ លេខសម្គាល់មួយនឹងត្រូវចេញឲ្យអ្នកដោយរដ្ឋ។

**7។ ជម្រើសបក្ស។** ការប្រកាសអំពីបក្សគឺមិនតម្រូវដើម្បីចុះឈ្មោះបោះឆ្នោតទេ។ ទោះជាយ៉ាងនេះក្តី ច្បាប់បោះឆ្នោតនៃរដ្ឋ Utah អនុញ្ញាតឲ្យបក្សនយោបាយនីមួយៗត្រូវបានជ្រើសដោយអ្នកដែលអនុញ្ញាតឲ្យបោះឆ្នោតបឋម។ ប្រសិនបើអ្នកមិនមានសម្ព័ន្ធជាមួយបក្សទេ អ្នកអាចនឹងត្រូវបានកម្រិតពីការបោះឆ្នោតបឋម។

**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ

**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Utah អ្នកត្រូវ៖
• ជាពលរដ្ឋសហរដ្ឋអាមេរិក
• បានស្នាក់នៅក្នុងរដ្ឋ Utah រយៈពេល 30 មុនការបោះឆ្នោតបន្ទាប់
• មានអាយុយ៉ាងតិច 18 ឆ្នាំនៅថ្ងៃ ឬមុនថ្ងៃការបោះឆ្នោតបន្ទាប់
• មិនត្រូវបានផ្តន្ទាទោសឧក្រិដ្ឋ និងត្រូវឃុំឃាំងសម្រាប់ការប្រព្រឹត្តបទឧក្រិដ្ឋ
• មិនត្រូវបានផ្តន្ទាទោសក្បត់ជាតិ ឬឧក្រិដ្ឋកម្មប្រឆាំងអាជីវកម្មបោះឆ្នោត លើកលែងតែត្រូវបានផ្តល់សិទ្ធិពលរដ្ឋឡើងវិញ
• មិនត្រូវបានកំណត់ថាជាអសមត្ថជនផ្នែកស្មារតីដោយតុលាការ

**អាស័យដ្ឋានប្រៃសណីយ៍**
ការិយាល័យអភិបាលឯក
P.O. ប្រអប់ 142325
Salt Lake City, UT 84114

## រដ្ឋ Vermont

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី29 ខែកក្កដា ឆ្នាំ2008**

**កាលកំណត់ចុះឈ្មោះ** — ប្រគល់ទៅស្មៀនទីក្រុងមុនម៉ោង 5:00 ល្ងាចនៅថ្ងៃពុធមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** អ្នកត្រូវផ្តល់លេខបណ្ណបើកបរនៃរដ្ឋ Vermont ឬប្រសិនបើមិនមាន លេខសន្តិសុខសង្គមបួនខ្ទង់ចុងក្រោយ។ ប្រសិនបើអ្នកមិនមានបណ្ណបើកបររដ្ឋ Vermont ឬលេខសន្តិសុខសង្គមទេ ចូរសរសេរ “គ្មាន” នៅលើទម្រង់នេះ។ ការិយាល័យរដ្ឋមន្ត្រីនឹងផ្តល់លេខសម្គាល់អត្តសញ្ញាណមួយឲ្យអ្នក។

**7។ ជម្រើសបក្ស។** រដ្ឋ Vermont មិនតម្រូវការចុះឈ្មោះបក្សក្នុងការចូលរួមការបោះឆ្នោតណាមួយទេ។

**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ

**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Vermont អ្នកត្រូវ៖
• ជាពលរដ្ឋសហរដ្ឋអាមេរិក
• មានលំនៅនៅរដ្ឋ Vermont
• មានអាយុ 18 ឆ្នាំនៅមុន ឬនៅថ្ងៃបោះឆ្នោត
• ត្រូវបានសច្ចាប្រណិធានដូចខាងក្រោម៖ អ្នកសច្ចាប្រណិធាន (បញ្ជាក់) យ៉ាងដាច់ខាតថា ទោះនៅពេលណាក៏ដោយអ្នកនឹងផ្តល់សន្លឹកឆ្នោត ឬបោះឆ្នោត។ រឿងដែលប៉ះពាល់ដល់រដ្ឋ Vermont អ្នកនឹងធ្វើវាប្រកបដោយមនសិកាដែលអ្នកនឹងសម្រេចឲ្យបានម៉តចត់អំពីភាពល្អបំផុតដូចគ្នាដូចបានបង្កើតដោយរដ្ឋធម្មនុញ្ញដោយគ្មានភ័យខ្លាចឬការពេញចិត្តបុគ្គលមួយ

ទេ [ ការសច្ចាប្រណិធានរបស់អ្នកបោះឆ្នោត រដ្ឋធម្មនុញ្ញរដ្ឋ Vermont ជំពូកទី II ផ្នែក 42 ]
ដោយការចុះហត្ថលេខាក្នុងប្រអប់ទី 9 អ្នកទទួលស្គាល់ថា អ្នកបានស្បថសច្ចាប្រណិធាន ឬបញ្ជាក់អះអាងនូវសច្ចាប្រណិធានរបស់អ្នកបោះឆ្នោតរដ្ឋ Vermont ដូចមាននៅខាងលើ។

**អាស័យដ្ឋានប្រៃសណីយ៍**
ការិយាល័យលេខាធិការរដ្ឋ
នាយកការបោះឆ្នោត
26 Terrace Street
Montpelier, VT 05609-1101

## រដ្ឋ Virginia

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី30 ខែវិច្ឆិកា ឆ្នាំ2011**

**កាលកំណត់ចុះឈ្មោះ** — បានបញ្ជូន 22 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ** លេខសន្តិសុខសង្គមពេញរបស់អ្នកគឺជាតម្រូវការចាំបាច់។ លេខសន្តិសុខសង្គមរបស់អ្នកនឹងបង្ហាញនៅលើរបាយការណ៍ដែលត្រូវបានរៀបចំសម្រាប់មន្ត្រីប្រើដោយការចុះឈ្មោះអ្នកបោះឆ្នោតនិងមន្ត្រីបោះឆ្នោតប៉ុណ្ណោះ សម្រាប់គោលបំណងជ្រើសរើសគណៈកម្មការដោយតុលាការ។ មាត្រា II, §2, រដ្ឋធម្មនុញ្ញរដ្ឋ Virginia (1971).
**7។ ជម្រើសបក្ស។** អ្នកមិនចាំបាច់ត្រូវតែចុះឈ្មោះជាមួយបក្សទេ ប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬសមាជ។
**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ។
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះក្នុងរដ្ឋ Virginia អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- ស្នាក់នៅរដ្ឋ Virginia និងនៅកន្លែងដែលអ្នកចង់បោះឆ្នោត
- មានអាយុ 18 ឆ្នាំត្រឹមខែឧសភា ឬខែវិច្ឆិកានៃការបោះឆ្នោតសកលបន្ទាប់
- មិនត្រូវបានផ្តន្ទាទោសឧក្រិដ្ឋ ឬបានទទួលសិទ្ធិពលរដ្ឋឡើងវិញ
- មិនត្រូវបានសម្រេចសេចក្តីថាជាអសមត្ថភាពផ្នែកស្មារតីដោយតុលាការថ្មីៗ

**អាស័យដ្ឋានប្រៃសណីយ៍**
ក្រុមប្រឹក្សារដ្ឋ Virginia
នៃការបោះឆ្នោត
1100 Bank Street, 1st floor
Richmond, VA 23219

## រដ្ឋ Washington

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី24 ខែកញ្ញា ឆ្នាំ2012**

**កាលកំណត់ចុះឈ្មោះ** — 29 ថ្ងៃមុនការបោះឆ្នោត (ឬផ្តល់ដោយបុគ្គលផ្ទាល់ទៅមន្ត្រីចុះឈ្មោះមូលដ្ឋានរហូតដល់ 8 ថ្ងៃមុនការបោះឆ្នោត)។

**6។ លេខអត្តសញ្ញាណបណ្ណ** អ្នកត្រូវផ្តល់លេខអត្តសញ្ញាណប័ណ្ណរដ្ឋ ឬប័ណ្ណបើកបរនៃរដ្ឋ Washington របស់អ្នក។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបររបស់រដ្ឋ Washington ឬអត្តសញ្ញាណប័ណ្ណទេ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ការខកខានផ្តល់ព័ត៌មាននេះអាចរារាំងពាក្យស្នើសុំចុះឈ្មោះរបស់អ្នកពីដំណើរការ។
**7។ ជម្រើសបក្ស។** អ្នកមិនតម្រូវឲ្យបង្ហាញសម្ព័ន្ធបក្សរបស់អ្នកក្នុងការចុះឈ្មោះបោះឆ្នោតទេ។
**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Washington អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- មានលំនៅស្ថានស្របច្បាប់នៅរដ្ឋ Washington ខោនធីនិងកន្លែងរបស់អ្នកសម្រាប់រយៈពេល 30 ថ្ងៃមុនការបោះឆ្នោតដែលអ្នកចង់បោះឆ្នោត
- មានអាយុយ៉ាងតិច 18 ឆ្នាំនៅថ្ងៃបោះឆ្នោត
- មិនត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌ លើកលែងតែត្រូវបានផ្តល់សម្បទាសិទ្ធិពលរដ្ឋឡើងវិញ

**អាស័យដ្ឋានប្រៃសណីយ៍**
រដ្ឋមន្ត្រី
ផ្នែកការបោះឆ្នោត
P.O. ប្រអប់ 40229
Olympia, WA 98504-0229

## រដ្ឋ West Virginia

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី12 ខែកញ្ញា ឆ្នាំ2006**

**កាលកំណត់ចុះឈ្មោះ** — 21 ថ្ងៃមុនការបោះឆ្នោត។

**6។ លេខអត្តសញ្ញាណបណ្ណ**
សូមបញ្ចូលលេខប័ណ្ណបើកបររបស់អ្នក។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបរ អ្នកត្រូវផ្តល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។ ប្រសិនបើអ្នកមិនមានលេខប័ណ្ណបើកបរ ឬលេខសន្តិសុខសង្គមទេ លេខសម្គាល់អត្តសញ្ញាណនឹងផ្តល់ឲ្យអ្នក។
**7។ ជម្រើសបក្ស។** អ្នកត្រូវចុះឈ្មោះជាមួយបក្សប្រសិនបើអ្នកចង់ចូលរួមនៅក្នុងការបោះឆ្នោតបឋមរបស់បក្សនោះ ជាការប្រជុំបក្ស ឬអនុសញ្ញា (លើកលែងតែសន្លឹកឆ្នោតនៃគណបក្សដែលអនុញ្ញាតអ្នកឯករាជ្យបោះឆ្នោត)
**8។ សាសន៍ ឬក្រុមជនជាតិ**
សូមទុកឲ្យនៅទំនេរ
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះក្នុងរដ្ឋ West Virginia អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- រស់នៅក្នុងរដ្ឋ West Virginia នៅអាសយដ្ឋានខាងលើ
- មានអាយុ 18 ឆ្នាំ ឬដើម្បីបោះឆ្នោតបឋមត្រូវមានអាយុ 17 ឆ្នាំនិងត្រូវឈានចូលអាយុ 18 ឆ្នាំមុនការបោះឆ្នោតសកល
- មិនត្រូវស្ថិតក្រោមការផ្តន្ទាទោសការឃុំខ្លួនបណ្តោះអាសន្ន ឬការឲ្យនៅក្រៅឃុំសម្រាប់បទឧក្រិដ្ឋ ក្បត់ជាតិ ឬបន្លំសន្លឹកឆ្នោត
- មិនត្រូវបានសម្រេចសេចក្តីថាជា "មនុស្សអសមត្ថភាពផ្នែកស្មារតី" ដោយតុលាការមានសមត្ថកិច្ច

**អាស័យដ្ឋានប្រៃសណីយ៍**
រដ្ឋមន្ត្រី
Building 1, Suite 157-K
1900 Kanawha Blvd. East
Charleston, WV 25305-0770

# ការណែនាំរដ្ឋ

## រដ្ឋ Wisconsin

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី05 ខែសីហា ឆ្នាំ2013**

**កាលកំណត់ចុះឈ្មោះ** — ផ្ញើតាមប្រៃសណីយ៍យ៉ាងតិចម្ភៃថ្ងៃមុនការបោះឆ្នោត ឬបានបំពេញនៅការិយាល័យក្រុងភូមិ ឬទីក្រុងរហូតដល់ម៉ោង 5:00 ល្ងាច ឬបិទការងារនោះបើយឺតក្ដី នៅថ្ងៃសុក្រមុនការបោះឆ្នោត ឬបានបំពេញនៅកន្លែងបោះឆ្នោតនៅថ្ងៃបោះឆ្នោត

**6។ លេខអត្តសញ្ញាណបណ្ណ** សូមផ្ដល់លេខអត្តសញ្ញាណប័ណ្ណដែលចេញដោយ DOT ឬប័ណ្ណបើកបររបស់អ្នក។ ប្រសិនបើអ្នកមិនមានប័ណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណចេញដោយ DOTទេ អ្នកត្រូវផ្ដល់លេខ 4 ខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។
**7។ ជម្រើសបក្ស។** មិនបានតម្រូវ។
**8។ សាសន៍ ឬក្រុមជនជាតិ** មិនបានតម្រូវ។
**9។ ហត្ថលេខា។** ដើម្បីចុះឈ្មោះនៅក្នុងរដ្ឋ Wisconsin អ្នកត្រូវ៖
- ជាពលរដ្ឋសហរដ្ឋអាមេរិក
- ស្នាក់នៅក្នុងរដ្ឋ Wisconsin និងស្នាក់នៅអាស័យដ្ឋានចុះឈ្មោះយ៉ាងតិច 28 ថ្ងៃ។
- មានអាយុ 18 ឆ្នាំ។
- មិនត្រូវផ្ដន្ទាទោសក្បត់ជាតិ ឧក្រិដ្ឋ ឬបន្លំសន្លឹកឆ្នោត ឬប្រសិនបើត្រូវបានផ្ដន្ទាទោស រាល់សិទ្ធិពលរដ្ឋរបស់អ្នកត្រូវបានសម្បទាឡើងវិញ
- មិនត្រូវបានរកឃើញដោយតុលាការថា អសមត្ថភាពខាងយល់ដឹងនៃដំណើរការបោះឆ្នោត
- មិនបង្កើតឬទទួលប្រយោជន៍ពីការភ្នាល់ឬប្រាក់ឈ្នួលអាស្រ័យលើលទ្ធផលនៃការបោះឆ្នោត
- មិនបានបោះឆ្នោតនៅទីតាំងផ្សេង ប្រសិនបើចុះឈ្មោះនៅថ្ងៃបោះឆ្នោត

**អាស័យដ្ឋានប្រៃសណីយ៍**

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវរដ្ឋាភិបាល
212 East Washington Avenue, Third Floor
P.O. ប្រអប់ 7984
Madison, WI 53707-7984

## រដ្ឋ Wyoming

**បានធ្វើបច្ចុប្បន្នភាព៖ ថ្ងៃទី01 ខែមីនា ឆ្នាំ2006**

តាមផ្លូវច្បាប់រដ្ឋ Wyoming មិនអាចទទួលទម្រង់នេះទេ លើកលែងតែច្បាប់រដ្ឋត្រូវបានធ្វើវិសោធនកម្ម។